N° 3
-Kambuja Suriya-
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

---

INSTITUT BOUDDHIQUE

ឆ្នាំទី ២៥ ខែមីនា លេខ ៣
-Mars-
ព.ស. ២៤៩៥ — គ.ស. ១៩៥៣

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K_1
1953_3

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — វិជ្ជាទិកថា ................ | ព្រះមហា ជាប — ប៊ិន ...... | ១៦៣ |
| — សង្គាយនាព្រះត្រៃបិដកប្រទេសកម្ពុជា .. | ពុទ្ធសាសនបណ្ឌិត្យ ....... | ១៧៩ |
| — កបិលកថា ................ | ព្រះមហាឧត្តមវិជ្ជា កែ—ធឿន .. | ១៩២ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — ការបណ្ដុះនិស្ស័យ (តមក)....... | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... | ១៩៦ |
| — រឿងសាមកុក (តមក).......... | ឧកញ៉ា ឡូ - កន .......... | ២០៣ |
| — រឿងអារ័ក្សថ្លែងរឿងម្ដៃប្រាំ (តមក )... | លោក ប៉ាយ - ប៊ុក.......... | ២១០ |
| — រឿងស្លាប់ព្រោះជាតិ (តមក)....... | លោក គង់ — លឹម......... | ២១៧ |
| — រឿងប៉ូលនឹងវីរ៉ស៊ីនី (តមក) ....... | លោក ផេង - ស្រីវ.......... | ២២៤ |
| **កំណត់នឹងប្រវត្តិការណ៍** | | |
| —សន្និសីទព្រះពោធិវង្ស ហួត - តាត អំពី សមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ ... | ២២៩ |
| —សុន្ទរកថាបណ្ឌិតម៉ាឡាល៉ះសេកេរៈថ្លែងក្នុង សមាជសាកលលើកទី ២ នៃពុទ្ធសាសនា | (តមក) ពុទ្ធសាសនបណ្ឌិត្យ... | ២៣៤ |
| —បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី(តមក) | ក្រសួងធម្មការ .......... | ២៣៩ |

មួយឆ្នាំមាន ១២ សៀវភៅ — ថ្លៃជាវ ១៩២រ.០០

### កឋិនកថា

របៀបទេសនាបុច្ឆា - វិសជ្ជនា

## ព្រះមហាឧត្តមវិជ្ជា កែ - អឿន (វីរិយបញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ព្រះទេពសត្ថា សួរ - ហាយ ពិនិត្យកែសម្រួល

---

### អារម្ភកថា

ហេតុដែលនាំឲ្យកើតជាសៀវភៅ កឋិនកថា បុច្ឆា - វិសជ្ជនានេះ ឡើង គឺកើតឡើងដោយលោកឡែម - រឿន ជាអតីតមេឃុំសៀមរាប និង ឧបាសិកា ទូច ជាភរិយា មានសទ្ធាជ្រះថ្លាធ្វើកឋិនទានដង្ហែទៅវេរប្រគេន ព្រះសង្ឃវត្តពោធិលង្កា ខេត្តសៀមរាប ក្នុងឆ្នាំជូតនក្សត្រសំរិទ្ធិស័ក ព. ស. ២៤៩១, គ. ស. ១៩៤៨ មានប្រាថ្នាចង់បានសៀវភៅកឋិនទាន ដើម្បីសំដែងក្នុងឱកាសបុណ្យនោះ រួចហើយនឹងហែយកទៅជាមួយអង្គ កឋិន ដាក់ទុកជាធម្មទានក្នុងវត្តនោះផង បានទៅនិមន្តខ្ញុំឲ្យរៀបរៀង កឋិន និងអានិសង្សកឋិនទានជារបៀបបុច្ឆា - វិសជ្ជនា ទំនងដូចជាធម្ម-កថិកទេសនាគ្រែពីរ ៗ ខ្ញុំក៏ពេញចិត្តក្នុងការនេះដែរ ខំប្រឹងប្រែងរៀប រៀងត្រាតែបានសម្រេច ។ កាលនឹងរៀបរៀងខ្ញុំបានយកគម្ពីរនឹងច្បាប់ ជាច្រើន ដែលលោកអ្នកប្រាជ្ញបានរៀបរៀងទុកមកពីមុនខ្លះ ទាំងបាន

ឃើញសាស្ត្រាភាគិសង្ក្រងប៉ិនស៊ីករិត ១ ខ្សែ បំណាំងជើងថា ជាស្នាដៃរបស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ្រីតែង, បានពិនិត្យមើលសព្វគ្រប់ មានសេចក្តីពីរោះប្លែកជាទីគាប់ចិត្តដែលមិនដែលមានក្នុងច្បាប់នានា ក៏បានដកស្រង់យកមករៀបរៀងឲ្យកើតបានជាច្បាប់នេះ ។ លុះរៀបរៀងរួចហើយ ខ្ញុំបានយកសំណៅនោះទៅឲ្យលោកមហាជាប្រិនអគ្គ ឲ្យជួយពិនិត្យកែសម្រួលសេចក្តី ។ លោកទាំងនោះក៏ជួយពិនិត្យដោយម៉ត់ចត់, ពិនិត្យរួចហើយ លោកខ្សែម-វឿនបានជួលអ្នកចារសាស្ត្រាឲ្យចារដាក់ស្លឹករឹតបំបែកជាពីរខ្សែ គឺមហាថេរ អ្នកសួរ ១ ខ្សែ អនុត្តរ អ្នកឆ្លើយ ១ ខ្សែ ។

ដល់ពេលកំណត់បុណ្យកឋិននោះ លោកខ្សែម-វឿនបាននិមន្តភិក្ខុពីររូបទៅសំដែងតាមសេចក្តីដែលរៀបរៀង, ពុទ្ធបរិស័ទបានជួបជុំស្តាប់ធម៌នេះជាច្រើន សឹងសរសើរថាពីរោះរាល់គ្នា ហើយក៏សូមយកច្បាប់នោះទៅចារចម្លងតៗ ទៅចំនួន ២០ ច្បាប់ទៀត ។

ច្បាប់នេះ ខ្ញុំមានបំណងនឹងបោះពុម្ពជាសៀវភៅយូរហើយ តែមិនមានពេលឱកាសនឹងធ្វើបាន ទើបតែពេលនេះទំនៀតពេលដកស្រង់ជាថ្មី បានកែសម្រួលសេចក្តីថែមទៀត ។

លុះកែសម្រួលសេចក្តីរួចហើយ ឲ្យលោកមហាដដែលជួយកែសម្រួល

ទៀត ហើយឲ្យកុំគុយ៉ាន-ឃុិន ធម្មកោសលត្រីនឹងធម្មកោសលទោ ឲ្យជួយសរសេរចម្លងយកមកបោះពុម្ពជាសៀវភៅឡើង ។

សៀវភៅ កឋិនកថា បុប្ផា-វិសុទ្ធានេះ មានប្រយោជន៍ទូទៅ ទាំងគ្រហស្ថ បព្វជិត, ខាងចុងសៀវភៅនេះមានបាលីវេរកឋិននឹងពិធីក្រាលគ្រងកឋិនជាដើមដោយសព្វគ្រប់ ។

ដោយអំណាចវីរិយភាព ដែលខ្ញុំបានរៀបរៀងកឋិនកថា បុប្ផា-វិសុទ្ធានេះ សូមឲ្យសាសនមណ្ឌលនៃព្រះទសពលញាណប្រតិស្ឋានគ្រប់ ៥ ពាន់ព្រះវស្សា !

ម្យ៉ាងទៀតសូមឲ្យលោកអ្នកសិក្សាទាំងឡាយបានសម្រេចសមតាមវត្ថុបំណងកុំបីឃ្លៀងឃ្លាតឡើយ !

សូមអភ័យទោសអំពីសំណាក់បណ្ឌិតទាំងឡាយ បើឃើញមានសេចក្ដីភាំងភាត់ធ្គាំធ្គងត្រង់កន្លែងណាមួយ មេត្តាជួយកែតម្រង់ឲ្យបានដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនា ។

វត្តព្រះព្រហ្មរតន៍ ថ្ងៃចន្ទ ១ កើតខែមិគសិរ ឆ្នាំរោងចត្វាស័ក ព.ស. ២៤៩៥ ត្រូវនឹងថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ១៩៥២ ។

ព្រះមហាឧត្ដមវិជ្ជា

កែ-អឿន

# កប៉ងកថា

## បុច្ឆា-វិសជ្ជនា

អាត្មាភាពទាំងពីររូប សូមចំរើនពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ។ ពរទាំង ៤ ប្រការនេះ ចូរវឌ្ឍនាការចំរើនដល់ពុទ្ធបរិស័ទទាំងឡាយ ដែលមានចិត្តសោមនស្សស្មោះសរ ត្រេកអរក្នុងការកុសលផល សីលទាន ជាញាណសម្បយុត្តខ្លះ ជាញាណវិប្បយុត្តខ្លះ ដោយសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យទ្រគុណជាបុញ្ញក្ខេត្ត, មានបច្ច័យជួយឧបត្ថម្ភនាំឲ្យកើតបុញ្ញកម្ម ទើបមកសន្និបាតប្រជុំគ្នាក្នុងទីនេះ ដើម្បីនឹងស្តាប់ព្រះសទ្ធម្មវិសេសទេសនា បានអារាធនានិមន្តអាត្មាភាពទាំងពីររូបមកសំដែងថ្វាយព្រះសទ្ធម្មទេសនាបុច្ឆា-វិសជ្ជនា ជាបដិការៈតបស្នងនូវសទ្ធា ទោះបីបើអាត្មាភាពទាំងពីររូប សំដែងទៅហើយក្រែងមានភ្លាំងភ្លាត់ខាតខុសលើសលោះ ដោយបទបាទអក្ខរៈព្យញ្ជនៈបាលីឬសេចក្តីអធិប្បាយត្រង់ណាមួយ ដោយឥតមានចេតនាក្លែងក្លាយ សូមលោកអ្នកទាំងឡាយខន្តីអភ័យទោស ដល់អាត្មាភាពទាំងពីររូប នឹងបានសំដែងតាមដោយនូវដំរិះប្រាជ្ញាអន់ថយ

សូមចំរើនពរ ។

### គាប់ឆកថា

របៀបទេសនា បុញ្ញា - វិសជ្ជនា

## ព្រះមហាឧត្តមវិជ្ជា កែ - អឿន វីរិយប្បញ្ញោ

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ព្រះទេពសត្ថាស្សូរ - ហាយ ពិនិត្យកែសម្រួល

(តមក)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះប្រជុំ ៣ នៃព្រះរតនៈ គឺព្រះពុទ្ធ ព្រះធម៌ និង ព្រះសង្ឃ ដោយសេចក្ដីគោរព ។

ឥមិនាបិ បណាមេន សទា សោត្ថី ភវន្តុ វោ

ដោយកិរិយាប្រណាម្យថ្វាយបង្គំ ចំពោះគុណព្រះរតនត្រ័យនេះឯង សូមសិរីសួស្ដីចំរើនដល់ពុទ្ធបរិស័ទទាំងឡាយ ឲ្យបានសព្វៗ កាល រៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

ឥតោ បរំ តអំពីបទនមស្ការនេះទៅ នឹងបានសំដែងព្រះសទ្ធម្ម-វិសេសទេសនា ជារបៀបបុញ្ញា - វិសជ្ជនា អំពីកឋិនទាន ព្រមទាំង អានិសង្សនៃកឋិនទាន; តែមុននឹងសំដែងនេះ សូមសន្តត់ខណិកនាម ទៅវិញទៅមកសិន ចំណែកអាត្មាភាពខាងណេះ គួរបាននាមថាជា

"មហាថេរៈ" ដោយមានវស្សាច្រើនជាង, ចំណែកលោកម្ចាស់ខាងណោះត្រូវបាននាមជា "អនុត្តរៈ" ដោយមានវស្សាតិចជាងអាត្មាភាព ។

អនុត្តរៈ ម្នាលអនុត្តរ! សូមលោកម្ចាស់ផ្ចង់ ដម្រង់ស្មារតីផ្ទៀងសោតប្រសាទចាំស្ដាប់ខ្ញុំនឹងបុច្ឆាសួរក្នុងកាលឥឡូវនេះ ។

១.– ម្នាលអនុត្តរ! អ្វីដែលហៅថា កប្បិន? សូមនិមន្តវិសជ្ជនាមកមើល ។

អនុត្ត មហាថេរៈ បពិត្រមហាថេរដ៏ចំរើន! ដំណើរការណ៍ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងបញ្ញត្តិបរមត្ថរូបធម៌ និងនាមធម៌ទាំងឡាយបានឈ្មោះថា កប្បិន, នឹងបានឈ្មោះថា កប្បិន ដោយបរមត្ថធម៌ក៏ទេ, ពាក្យថា កប្បិន ជាធម៌ឯកដោយវិសេសប្លែកជាងពានទាំងពួង ហៅថា កប្បិន, សូមទានជ្រាប ។

២.– សាធុ សាធុ ម្នាលអនុត្តរ! ចុះកប្បិន-សព្ទនេះ បើប្រែតាមធាតុ បានសេចក្តីដូចម្តេច? បើប្រែតាមអត្ថជាដូចម្តេច? សូមនិមន្តប្រែមកហើយអធិប្បាយឲ្យល្មមខ្ញុំស្ដាប់បានផងមើល ។

– បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណានឹងប្រែតាមធាតុ រួចប្រែតាមអត្ថ ទោះបើល្មមស្ដាប់បានបន្តិចបាននោះមិនអាចជានាទេ ។ កប្បិន សព្ទនេះ បើប្រែតាមធាតុ អដ្ឋកថាប្រាប់ថា ធាតុដើមជា "កប" ប្រព្រឹត្តទៅក្នុងអត្ថពីរយ៉ាង ថា "កិរិយារស់នៅដោយក្រ" ១ ថា "កិរិយាពាល

សរសើរ" ១; ឯអត្ថថា "រស់នៅដោយក្រ" នោះ ដូចឈើស្នឹងដែលបុគ្គលកាត់យកឈើស្រស់មកបោះធ្វើជាស្នឹង ឯឈើស្នឹងនោះរស់ដុះលូតលាស់ឡើងបានដោយក្រពេក មានសេចក្ដីឧបមាយ៉ាងណា ឯកឋិនទានដែលទឹងកើតឡើងតាំងឡើងពេញទីជាកឋិនបានដោយក្រពន់ពេក មានឧបមេយ្យដូច្នោះដែរ ។ ចំណែកអត្ថថា "ពោលសរសើរ" នោះ គឺតែទានដ៏វិសេសដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះពុទ្ធជាដើមតែងពោលសរសើរថា "មានផលដ៏វិសេស សម្រេចដល់បុគ្គលទាំងពីរខាង គឺខាងទាយកអ្នកឲ្យក៏បានអានិសង្សច្រើន, ខាងបដិគ្គាហកភិក្ខុអ្នកទទួលក្រាលកឋិនទឹងបុគ្គល គណៈ ឬសង្ឃដែលអនុមោទនាក៏បានសម្រេចអានិសង្សទាំង ៥ ពេញទីដល់អស់កឋិនក្ខេត្ត" ។ កឋិន - សព្ទនេះ បើប្រែតាមអត្ថគឺសេចក្ដីមានពីរយ៉ាង ថា "កាន់យកព្រម" ១ ថា "ស្ថិតស្ថេរ" ១ ។ ឯពាក្យថា "កាន់យកព្រម" គឺភិក្ខុអ្នកក្រាល ឬភិក្ខុអ្នកអនុមោទនាអាចកាន់យកនូវអានិសង្ស ៥ មិនឲ្យគេចហួសទៅខាងដទៃបាន; ពាក្យថា "ស្ថិតស្ថេរ" គឺភិក្ខុអ្នកក្រាលទឹងភិក្ខុអ្នកអនុមោទនាកឋិនអាចធ្វើនូវអានិសង្ស ៥ ឲ្យមានទីបំផុតត្រឹមពេញបូណ៌មីខែផល្គុន ឬថាតាំងនៅគង់ខាងក្នុងនៃកឋិនក្ខេត្ត ។ អធិប្បាយថាបើភិក្ខុបានក្រាលត្រង់ឬអនុមោទនាកឋិនតាំងពីថ្ងៃ ១ កើតខែអស្សុជទៅ អានិសង្សកឋិនមាន ៥ ខែ, បើបានក្រាលឬអនុមោទនាកឋិន តាំងពីថ្ងៃពេញបូណ៌មីខែកត្តិកទៅ នោះ

អានិសង្សទាំង ៥ ទាំងស្ថិតស្ថេរនៅអស់កំណត់ហេមន្តរដូវត្រឹមតែ ៤ ខែ; បពិត្រព្រះមហាថេរដ៏ចំរើន! ខ្ញុំព្រះករុណាបាននាំប្រែកឋិន សព្វព្រមទាំងសេចក្ដីអធិប្បាយបានសេចក្ដីប៉ុណ្ណេះ សូមជ្រាប ។

ញ.— សាធុ សាធុ លោកម្ចាស់វិសជ្ជនាមកនេះ ខ្ញុំស្ដាប់បានចូលចិត្តហើយ ខ្ញុំនឹងសួរតទៅទៀត ។ អើលោកម្ចាស់! កឋិននេះ មានពីត្រឹមណាមក? មានដំណើររឿងរ៉ាវដូចម្ដេច បានជាព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យមានកឋិននេះឡើង? សូមលោកម្ចាស់និមន្តសំដែងឲ្យពិរោះក្បោះក្បាយមកមើល ។

— ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! ការសំដែងឲ្យពិរោះក្បោះក្បាយនោះពុំអាចអះអាងបានទេ ឯរឿងកឋិននេះមាននិទានជាវិត្ថារពិស្ដារ សូមសំដែងតាមសមត្ថភាពនៃការចេះដឹង ចំពោះកឋិនដែលមាននៅក្នុងកឋិនក្ខន្ធកៈ ដែលព្រះសង្គីតិកាចារ្យទាំងឡាយមានព្រះមហាកស្សបត្ថេរ ជាប្រធាន លោកសង្គាយនាតាំងទុកមកថាៈ—

សម័យមួយ សម្ដេចព្រះភគវន្តបពិត្រ ស្ដេចស្ថិតគង់សំរាកក្សាន្តព្រះឥរិយាបថអភិរម្យដោយព្រហ្មវិហារប្រាកដនៅក្នុងព្រះមហាវិហារព្រះជេតពនសួនក្នុង ជាអាកមនៃអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ពុំឆ្ងាយអំពីនគរសាវត្ថីភពបុរីសីមា គ្រាកាលនោះ មានភិក្ខុទាំងឡាយប្រមាណ ៣០ អង្គ មានប្រក្រតីគង់នៅក្នុងនគរបាវា បបួលគ្នាត្រេចចោចរទៅ

កាន់នគរសាវត្ថី ប្រយោជន៍ដើម្បីនឹងចូលទៅគាល់ព្រះបរមសាស្តាចារ្យ វេលានោះជាវស្សូបនាយិកាសម័យ ជូនព្រះសង្ឃនឹងចូលព្រះវស្សាហើយ ឯភិក្ខុទាំង ៣០ រូបនោះ មានដំណើរមកក្នុងមគ្គាដ៏ឆ្ងាយ នឹងស្រូតទៅឲ្យដល់នគរសាវត្ថីពុំទាន់ ក៏ល្មមដល់ថ្ងៃចូលវស្សា ទើបនាំគ្នាចូលទៅអាស្រ័យចាំវស្សានៅក្នុងក្រុងសាកេត ជាខេត្តទៀងនគរសាវត្ថី អស់ចំនួនខែ ៣ តាមសម័យត្រៃមាសជាកំណត់ លុះដល់ចេញវស្សាបវារណាហើយ ភិក្ខុទាំង ៣០ រូបនោះ ក៏បបួលគ្នាលាចេញអំពីស្រុកសាកេតបុរី ធ្វើដំណើរទៅកាន់នគរសាវត្ថីកដស្ថានពុំទាន់បានដល់ ដោយផ្លូវឆ្ងាយសែនលំបាកក្រៃ ព្រោះសម័យនោះក៏ជាវស្សានរដូវ ផ្លូវនោះប្រកបដោយនូវទឹកភ្លៀងកក់ជ្រាប ឯចីវរស្បង់ សង្ឃាដីនៃភិក្ខុទាំងនោះ ក៏ជិតប្រឡាក់ទទឹកជោកដោយទឹកភ្លៀងតែរៀងៗរាល់ដំបន់រាល់កន្លែង, ឯសរីរៈកាយនៃភិក្ខុទាំងនោះឯង ក៏ទិត្យទៀយទ្រុឌទ្រោម លុះល្មមដល់នគរសាវត្ថី ទើបនាំគ្នាចូលទៅគាល់សម្តេចព្រះជិនស្រីក្នុងព្រះជេតពនមហាវិហារ ។ ឯព្រះដ៏មានព្រះភាគជាអគ្គបុគ្គល ស្តេចទ្រង់យល់ភិក្ខុទាំង ៣០ រូបនោះ ដែលមានត្រៃចីវរសៅហ្មងដោយនូវទឹកភ្លៀងទទឹកជ្រោះហើយ ទើបទ្រង់ត្រាស់បដិសណ្ឋារៈ សួរទុក្ខដោយពុទ្ធដីកាតាមធម្មតា ហើយទ្រង់ព្រះមហាករុណាក្នុងវេនេយ្យពុទ្ធបរិស័ទ អាស្រ័យហេតុនោះជានិទាន ទើបមានពុទ្ធដីកាត្រាស់ហៅភិក្ខុទាំងឡាយ មកប្រជុំសន្និបាត

ហើយទ្រង់អនុញ្ញាតកឋិនត្ថារវិនយកម្មថា "អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ "ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតឲ្យពួកភិក្ខុដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន" ។ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ចានិសំសានិ កប្បិស្សន្តិ "ម្នាល-ភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយបានក្រាលកឋិនហើយ នឹងបានសម្រេចអានិសង្ស ៥ ប្រការដោយពិត" ។ បពិត្រព្រះមហាថេរ! ឯដំណើរដើមដែលនាំឲ្យកើតកឋិនក្នុងសាសនា ដូចន័យដែលបានវិសជ្ជនាមកនេះ សូមបានជ្រាប ។

៤.– សាធុ សាធុ ម្នាលអនុត្ថេរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកពិរោះក្បោះក្បាយហើយ, ខ្ញុំសូមសួរតទៅទៀត ។ លោកម្ចាស់សំដែងថា "ភិក្ខុដែលបានក្រាលគ្រងកឋិន នឹងភិក្ខុដែលបានទទួលអនុមោទនានូវកឋិននោះ ថានឹងបានសម្រេចអានិសង្ស ៥ ប្រការ" ចុះអានិសង្ស ៥ ប្រការនោះតើអ្វីខ្លះ? សូមរៀបរាប់មកទៀតមើល ។

— បពិត្រព្រះមហាថេរ! ឯអានិសង្ស ៥ ប្រការ ដែលសម្រេចអំពីកឋិនមានដល់ពួកភិក្ខុនោះគឺ:

ក)— អនាមន្តចារោ ភិក្ខុណាពុំបានលាពុំបានប្រាប់ភិក្ខុជាសព្រហ្មចារី នៅក្នុងអារាមជាមួយគ្នា ហើយត្រាច់ទៅកាន់ត្រកូលក្នុងវេលាព្រឹកឬវេលាល្ងាច, ភិក្ខុនោះត្រូវអាបត្តិដោយពាក្យសិក្ខាបទ; ជា

បើភិក្ខុនោះបានត្រងកឋិនត្ថី អនុមោទនាកឋិនត្ថី ទោះបីមិនបានប្រាប់មិនបានលាភិក្ខុជាសព្រហ្មចារ្យនៅជាមួយគ្នា ហើយទៅកាន់ត្រកូល ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកឋិន អាចការពារអាបត្តិដល់ភិក្ខុនោះឯង ។

ខ)– អសមាទានចារោ. ភិក្ខុណាលះត្រៃចីវរឯណាមួយដែលជាទីរក្សាក្នុងកាលអរុណរះឡើងទុកហើយចេញចាកទីលំនៅ ឲ្យកន្លងអរុណមាត្រាតែរាត្រី ១ នឹងត្រូវអាបត្តិដោយចីវរវិកប្បនសិក្ខាបទ; បើភិក្ខុនោះបានក្រាលត្រងអនុមោទនាកឋិន ទោះបីលះត្រៃចីវរទុកឲ្យកន្លងរាត្រី ក៏ឥតត្រូវអាបត្តិ ព្រោះអានិសង្សនៃកឋិននោះឯង ។

គ)– គណភោជនំ ភិក្ខុទទួលបង្ហាន់គណភោជនតាំងតែអំពី ៤ រូបឡើងទៅ ហើយមានទាយកមកនិមន្តដោយវោហារគ្រហស្ថ មិនសមគួរដល់សមណកប្បជាដើមថា "និមន្តលោកឆាន់បាយ ឆាន់សម្ល ឆាន់ត្រី ឆាន់សាច់ជ្រូកជាដើម" ទៅឆាន់ក៏ត្រូវអាបត្តិដោយគណភោជនសិក្ខាបទ; បើភិក្ខុតាំងពី ៤ អង្គឡើងទៅ បានក្រាល បានអនុមោទនាកឋិនហើយ ទោះបីទៅឆាន់ភោជននៃទាយកនោះក៏ឥតត្រូវអាបត្តិ ។

ឃ)– យាវទត្ថចីវរំ ភិក្ខុបានចីវរលាភតាំងពីរួចមក ហើយពុំបានអធិដ្ឋានវិកប្ប ហើយទុកឲ្យកន្លងរាត្រី ១០ ថ្ងៃទៅផុតបេះក៏ពុំត្រូវអាបត្តិឡើយ ។

## ង)– យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ

ចីវរដែលកើតអំពីទាយកថ្វាយចំពោះជាសង្ឃទានក្តី ចីវរកើតអំពីធរ-ណីសង្ឃ គឺថ្ងៃស្រេចកឋិនវត្តក្តី មតកចីវរ គឺចីវររបស់ភិក្ខុសាមណេរដែលដល់អនិច្ចធម្មក្តី សង្ឃិកចីវរទាំង ៣ ប្រការ ដែលកើតក្នុងដែនកឋិនាកាស ក៏បានដល់ភិក្ខុដែលបានក្រាលអនុមោទនាកឋិនពួកមួយនោះឯង តែភិក្ខុដាច់វស្សាក្តី ភិក្ខុដែលចូលបច្ឆិមវស្សាគឺចូលក្នុងថ្ងៃ ១ កើតខែស្រាពណ៍នោះក្តី មិនត្រូវបានចំណែកចីវរនោះផងឡើយ ។

បពិត្រព្រះមហាថេរ ! ឯកឋិនទានមានអានិសង្សអាចការពារអាបត្តិ ៥ ប្រការ ដូចសំដែងមកនេះ ចំពោះមានកាលកំណត់ តាំងអំពីថ្ងៃដែលបានក្រាល-អនុមោទនាកឋិនមក ដរាបដល់ថ្ងៃបូណ៌មីខែផល្គុន ជាថ្ងៃបំផុតដោះកឋិនដោយប្រការដូច្នេះឯង សូមទានជ្រាប ។

(មានត)

កឋិនទាន មានក្នុង ពុទ្ធសាស្នា, ព្រះត្រាស់ថា បានផល ពីរចំណែក:
អ្នកផ្តល់ឲ្យ បានបុណ្យ អតិរេក តាមលោកចែក មានប្រាំ ប្រការណា ។
គឺអាយុ វណ្ណៈ នឹង សុខៈ ពលៈ បដិភាណ តាមតំរា
អ្នកទទួល តែងបាន អានិសង្ស ប្រាំប្រការ ការពារ អាបត្តិបាន ។

## កាលទានកថា

របៀបទេសនា បុច្ឆា-វិសជ្ជនា

ព្រះមហាឧត្តមវិជ្ជា កែ-អឿន វិរិយបញ្ញោ

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

ព្រះទេពសត្ថា ស៊ូរ-ហាយ ពិនិត្យកែសម្រួល

(តមក)

---

៥.– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! អនុត្តរសំដែងអំពីអានិសង្ស ៥ ប្រការ របស់ភិក្ខុដែលបានក្រាលកឋិនទឹងអនុមោទនាកឋិននោះពេញ ហៅត្រឹមត្រូវហើយ ចុះទាយកជាម្ចាស់ទាននោះ តើព្រះអនាវរណញ្ញាណ ទ្រង់សំដែងថាមានអានិសង្សដូចម្ដេចខ្លះ? សូមលោកម្ចាស់វិសជ្ជនាមក ។

– ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! កឋិនទាននេះ កាលបើសំដែងនូវផលដោយកាលទានសូត្រ ក៏ជាទក្ខិណាទានដ៏បរិបូណ៌ មានផលច្រើនតាំងអំពីអ្នកបរិច្ចាគ ទឹងអ្នកជួយខ្វល់ខ្វាយសមដូចបរិយាយក្នុងនិគមគាថា សម្ដេចព្រះមហាករុណាទ្រង់សំដែងក្នុងកាលទានសូត្រថា កាលេ ទទន្តិ សប្បញ្ញា វទញ្ញូ វីតមច្ឆរា ប៉ុណ្ណោះជាដើមសេចក្ដីថា បុគ្គលទាំងឡាយអ្នកមានប្រាជ្ញា ដឹងនូវពាក្យនៃអ្នកប្រាជ្ញ សន្ដានល្អ មានចិត្តកំណាញ់ប្រាសចាកហើយៗ បរិច្ចាគនូវវត្ថុទានផ្សេងៗ តាមសមគួរដោយសភាពអនុគ្រោះទឹងបូជា, កាលេន ទិន្នំ អរិយេសុ

ឧជុភូតេសុ តាទិសុ ទាយកអ្នកបរិច្ចាគទានបានឲ្យហើយដោយកាល ចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលលោកឆ្ងាយអំពីកិលេសវិសេស ដោយសេចក្ដីប្រតិបត្តិស្លូតត្រង់ ពុំឃ្លើសឃ្លង់ដោយកាយវាចាចិត្ត សុចរិតប្រព្រឹត្តស្មើ ពុំកក្រើកដោយអំណាចលោកធម៌ទាំង ៨ ប្រការ (១); វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា: ទានជាគ្រឿងចំរើនសម្បត្តិរបស់បណ្ឌិតជននោះៗ ជារបស់បុគ្គលមានចិត្តជ្រះថ្លា ហើយគួរជាទក្ខិណាបរិបូណ៌ដោយវិសេសជាវិបាកសម្បត្តិ, យេ ច តត្ថ អនុមោ-ទន្តិ វេយ្យាវច្ចំ ករោន្តិ វា ជនដទៃណាដែលពុំមែនជាម្ចាស់ទាន គ្រាន់តែជាអ្នកជួយអនុមោទនាត្រេកអរសាទរតាមទាយកនោះក្ដី ឬមួយជនដទៃណាជួយធ្វើវេយ្យាវច្ចកម្មខ្វល់ខ្វាយ យកកាយទៅបំរើកិច្ចការកឋិនទាននោះក្ដី, ន តេន ទក្ខិណា ឱនា ទក្ខិណាទានក៏ពុំមានថយចុះ ព្រោះហេតុនោះ, តេបិ បុញ្ញស្ស ភាគិនោ ជនទាំងឡាយដែលត្រេកអរតាមការជួយ ជាអ្នកមានចំណែកបុណ្យដែលបានអនុមោទនាជាបត្តានុមោទនាមយៈនឹងវេយ្យាវច្ចមយៈនោះ, តស្មា ទទេ អប្បដិ-វានចិត្តោ យត្ថ ទិន្នំ មហប្ផលំ ព្រោះហេតុដូច្នោះ សាធុជនជា

---

១ លោកធម៌ ៨ ប្រការគឺ: ១— លាភោ បានលាភ, ២— អលាភោ ឥតលាភ, ៣— យសោ មានយស, ៤— អយសោ ឥតយស, ៥— សុខំ សេចក្ដីសុខ, ៦— ទុក្ខំ សេចក្ដីទុក្ខ, ៧— និន្ទា ការតិះដៀល, ៨— បសំសា សេចក្ដីសរសើរ ។

បណ្ឌិតមិនគប្បីមានចិត្តរួញរាកំណាញ់ គប្បីឲ្យទៅទានចំពោះបដិគ្គាហកៈ ដែលគួរទទួលនូវទេយ្យទាននោះ ៗ ទាននោះឯងមានផលានិសង្សជាភិយ្យោភាពក្រៃលែងណាស់, បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ បុណ្យជាគ្រឿងចំរើនគួរជាទីពឹងពំនាក់នៃពួកសត្វក្នុងលោកទៅខាងមុខ ៗ កឋិនទាននេះ កាលបើសំដែងដោយគុណានិសង្សជាទក្ខិណាទានដ៏បរិបូណ៌សម្ផូរសេចក្តីក្នុងនិគមគាថា ក្នុងកាលទានសូត្រដោយប្រការដូច្នេះ ៗ ខ្ញុំបានវិសជ្ជនាមកអំពីអានិសង្សនៃកឋិនទានរបស់ទាយកជាម្ចាស់ទាន ដោយសេចក្តីសង្ខេបប៉ុណ្ណោះ សូមទានជ្រាប ៗ

៦.— សាធុ សាធុ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកពិរោះណាស់ហើយ ខ្ញុំនឹងសួរតទៅទៀត ៗ អើលោកម្ចាស់ ចុះហេតុអ្វីក៏ហៅថាកឋិនទាន? នឹងហៅថា ចីវរទាន វិញពុំបានទេឬ? សូមនិមន្តឆ្លើយពន្លឹកសេចក្តីឲ្យសព្វគ្រប់មកមើល ៗ

— បពិត្រព្រះមហាថេរ! បានជាហៅថាកឋិនទាននោះ បើនិយាយតាមបាលី ក្នុងខន្ធកវិន័យ ក៏មានអាការនឹងពិធីច្រើនយ៉ាងណាស់ តែសូមសំដែងតែខ្លី ៗ ល្មមស្តាប់ចូលចិត្តបាន, ដែលលោកហៅថាកឋិនទានព្រោះទានដើម្បីកឋិន ទាំងផលានិសង្សក៏មានពីរចំណែក គឺ: ទាយកអ្នកបរិច្ចាគនោះ ប្រកបដោយផលានិសង្សជាអសង្ខេយ្យចំណែក ១, ខាងបដិគ្គាហកៈ គឺភិក្ខុអ្នកទទួលសោតក៏ប្រកបដោយអានិសង្ស ៥ ប្រការ

ដូចបានសំដែងមកហើយនោះចំណែក ១ ៗ ហេតុនោះ ទាននេះទើបបាននាមហៅថាកឋិនទាន ដោយទាយកប្រាថ្នានឹងធ្វើទាននេះ មានកម្រិតកំណត់ត្រឹម ២៩ ថ្ងៃ ក្នុងមួយឆ្នាំប៉ុណ្ណោះ គឺតាំងពី ១ កើតខែអស្សុជ ដរាបទៅដល់ថ្ងៃពេញបូណ៌មីខែកត្តិក ជាបំផុតខេត្តកឋិន, បើផុតអំពី ២៩ ថ្ងៃទៅហើយ ទោះទាយកទាយិកា មានទ្រព្យមានសម្បត្តិមានសទ្ធាប៉ុន្មានៗ ក៏មិនអាចធ្វើបានឡើយ ទាននេះទើបថាកឋិនទានជាទានកម្រនឹងធ្វើបាន ៗ ចំណែកទានសង្ឃទានក្តី បាដិបុគ្គលិកទានក្តី ជាទានមិនមានកាលបរិច្ឆេទកំណត់កាលឡើយ, ស្រេចតែទាយកទាយិកាមានសទ្ធាជ្រះថ្លា ចង់ធ្វើថ្ងៃណាវេលាណា ក៏ធ្វើបានមិនមានហាមប្រាមដូចកឋិនទាននេះឡើយ, កឋិនទាននេះហើយ ជាទក្ខិណាទានប្លែកបដោយកម្រិតដោយទៀងទាត់ ទាំងមានផលវិសេសលើសទានទាំងពួង មួយទៀតកឋិនទាននេះ ជាការកម្រទាំងពីរយ៉ាងគឺទាយកអ្នកធ្វើ បើពុំឆ្លៀវឆ្លាសពុំចេះក្នុងការធ្វើ ក៏ទៅជាបាដិបុគ្គលិកទានវិញ ពុំពេញជាសង្ឃទាន ជាកឋិនទានឡើយ ចំណែកទានបដិគ្គាហកៈ គឺភិក្ខុអ្នកទទួល កាលបើពុំចេះក្នុងកឋិនត្ថារកិច្ច មិនចេះនូវបុព្វកិច្ច ៧ ប្រការមានកាត់-ដេរ-គក់-ជ្រលក់ជាដើម មិនចេះអានិសង្សទាំង ៥ ចាំនូវមាតិកាទាំង ៨ ក្តីមិនអាចដើម្បីធ្វើកឋិនត្ថារកិច្ចនោះបានឡើយ ៗ មួយទៀតការដែលលោកអ្នកគ្រងមិនទៀងជាកឋិននោះ សំដែងដោយអនុត្តរការ

២៤ប្រការ ដែលព្រះបរមសាស្ដាទ្រង់បញ្ញត្តទុកក្នុងកឋិនក្ខន្ធកៈ មានសេចក្ដីពិស្ដារណាស់ ពេលនេះគ្រាន់តែសំដែងពុទ្ធប្បញ្ញត្តិ ខាងទោសនៃត្រៃចីវរកឋិននោះដោយសង្ខេបៗ តាមន័យពុទ្ធប្បញ្ញត្តិថា "សំពត់ចីវរនោះបើពុំត្រូវខ្នាត ខាតមាត្រាតឹងប្រវែងហួសប្រមាណជាងចីវរព្រះសុគត ក៏ក្រាលមិនឡើងជាកឋិន ១, ត្រៃចីវរនោះពុំបានកាត់ជាកន្សែងតូចធំឲ្យជាបញ្ចខណ្ឌ, សត្តខណ្ឌ ឬដានវខណ្ឌ, ឬក៏ជាឯកាទសខណ្ឌ មិនត្រូវតាមរបៀបក្នុងវិន័យ ក៏ក្រាលមិនឡើងជាកឋិន ១, សំពត់នោះជាយវែងមានផ្កាលតាវល្លិ ឬជាផ្ទៃផ្សេងៗ ក៏ក្រាលមិនឡើងជាកឋិន ១, ចីវរនោះគឺគេជ្រលក់ដោយទឹករមៀត ទឹកល័ខព្រហ៊ូតលឿងខ្ចីដូចសំបុរក្នុកដំរី ឬក្រហមដូចព័ណ៌ស្វាទុំ ឬដកតាំ ឬសខ្មៅ ស្វាយ បៃតង ព្រាល ដូចសម្បុរមាស ឬសម្បុរផ្កាថា ក៏ក្រាលមិនឡើងជាកឋិនឡើយ ព្រោះហេតុនោះហើយបានជាកឋិនទាននេះពិបាកធ្វើណាស់ លុះតែអ្នកប្រាជ្ញឈ្លៀវឈ្លាសទើបធ្វើបាន; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាសំដែងមកដោយសង្ខេបៗ ប៉ុណ្ណេះ សូមទានជ្រាប ។

៧.– ម្នាលអនុគ្គេរ! ខ្ញុំជ្រាបហើយ តែខ្ញុំចង់ដឹងថា ឯព័ណ៌ចីវរដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យជ្រលក់ដោយទឹកអម្ចត់នោះតើមានប៉ុន្មានប្រការ គឺអ្វីខ្លះ? ព័ណ៌ជ្រលក់នោះ សំដៅយកព័ណ៌បែបណា ទើបសមគួរដល់សមណសារូបដែលអាចក្រាលឡើងជាកឋិនបាន?; សូមសំដែងតាមច្បាប់ឲ្យច្បាស់មកមើល ។

– ភន្តេ ថេរៈ បពិត្រព្រះថេរៈដ៏ចំរើន! ឯព័ណ៌ចីវរនោះព្រះសម្មា-សម្ពុទ្ធ ទ្រង់អនុញ្ញាតឲ្យកក់ចីវរក្នុងកៈថាមាន ៦ យ៉ាងដោយពុទ្ធដីកាថា អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនំ ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតទឹកជ្រលក់ ៦ យ៉ាង គឺទឹកជ្រលក់កើតអំពីមើម ១ ទឹកជ្រលក់កើតអំពីដើម ១ ទឹកជ្រលក់កើតអំពីសម្បក ១ ទឹកជ្រលក់កើតអំពីស្លឹក ១ ទឹកជ្រលក់កើតអំពីផ្កា ១ ទឹកជ្រលក់កើតអំពីផ្លែ ១; ទឹកជ្រលក់ទាំង ៦ យ៉ាងនេះ គឺសំដៅយកព័ណ៌លឿងលាយស្រអាប់ គួរយ៉ាងព័ណ៌ជ្រលក់ខ្ទឹមខ្ទរច្រើនលើកច្រើនដង បានព័ណ៌បែបណា ព័ណ៌បែបនោះ ហៅថាទឹកអម្ចត់ សមគួរដល់សមណសារូប ប្រើប្រាស់ស្លៀកដណ្តប់បាន, ថាបើចីវរនោះមានព័ណ៌ខុសនឹងសមណសារូប មានរមៀតអង្កោលៈព្រហ៊ូតជាដើមដូចបានសំដែងពីមុនមកហើយ គប្បីជ្រលក់ខ្ទឹមខ្ទរសង្កត់ព័ណ៌នោះចេញទើបគួរក្រាលឡើងជាកឋិន បានដោយត្រឹមត្រូវល្អ ។ បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាវិសជ្ជនាមក បានសេចក្តីដូចរៀបរាប់មកដូច្នេះ សូមទានជ្រាប ។

៨.– សាធុ សាធុ ម្នាលអនុត្ថេរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះត្រឹមត្រូវហើយ, ខ្ញុំនឹងលើកប្រស្នាដទៃសួរតទៅទៀត ។ អើ

លោកម្ចាស់ សំពត់យ៉ាងណាខ្លះ ដែលគួរធ្វើជាកឋិនបាន? សូមវិសជ្ជនា អធិប្បាយមកមើល ។

បពិត្រព្រះមហាថេរ! ឯសំពត់គួរធ្វើជាកឋិនបាននោះ, ព្រះភគវន្តមុនី ទ្រង់អនុញ្ញាតសំពត់ ៦ យ៉ាងគឺ ខោមំ សំពត់ដែលធ្វើពីសម្បកឈើ ១ កប្បាសិកំ សំពត់ដែលធ្វើពីប៉ុយកប្បាស ១ កោសេយ្យំ សំពត់ដែលធ្វើពីសូត្រ ១ កម្ពលំ សំពត់ដែលធ្វើពីរោមសត្វ (វៀរលែងតែធ្វើពីសក់មនុស្ស) ១ សាណំ សំពត់ដែលធ្វើពីសម្បកធ្មៃ ១ ភង្គំ សំពត់ដែលធ្វើពីរបស់ទាំង ៥ យ៉ាងខាងដើមនេះ ដែលគេត្បាញចម្រុះលាយគ្នា ដូចយ៉ាងសំពត់សូត្រលាយអំបោះជាដើម ១ សំពត់មានជាតិទាំង ៦ យ៉ាងនេះ ទោះជារបស់ថ្មីសុទ្ធក្តី, ជំនិក្តី, ចាស់ក្តី, ជាសំពត់បង្សុកូលគឺរបស់បានពីគំនរសម្រាមជាដើមក្តី, ជាសំពត់ធ្លាក់តាមរានផ្សារ (សំដៅយករបស់គេចោលមិនបាច់ទិញក្តី, មានព៌ណសក្តី, ព៌ណលឿងក្តី, ព៌ណដទៃតែអាចលាងឲ្យជ្រះព៌ណនោះចេញបានក្តី, ហើយជាសំពត់លាតគ្មានផ្កាទាក់ទងគ្នា ជាសំពត់ល្មមដេរតែត្រឹមស្បង់ ១ ប៉ុណ្ណោះក៏គួរធ្វើជាកឋិនបាន; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាបានវិសជ្ជនាមកអំពីសំពត់ដែលធ្វើជាកឋិនទានបាន ដូចសេចក្តីដែលបានសំដែងមកនេះ សូមទានជ្រាប ។ (មានត)

## កឋិនកថា

### របៀបទេសនាបុច្ឆា - វិសជ្ជនា

# ព្រះមហាឧត្តមវិជ្ជា កែ - អៀន (វីរយបុញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ព្រះទេពសត្ថា សួរ - ហាយ ពិនិត្យកែសម្រួល

(តមក)

៩.– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះត្រឹមត្រូវហើយ ៗ ចុះអ្នកណាខ្លះសមគួរជាទាយកធ្វើកឋិនទានបាន? សូមវិសជ្ជនាមកមើល ៗ

បពិត្រព្រះមហាថេរ! ឯអ្នកដែលសមគួរជាទាយកធ្វើកឋិនទានបាននោះ ពោលតាមគម្ពីរសមន្តបាឋថា យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចន្នំ សហធម្មិកានំ អញ្ញតរេន ទិន្នំ វដ្តតិ

"ឯអ្នកដែលសមគួរជាទាយកធ្វើកឋិនទានបាននោះ គឺ ទេវតាក្តី មនុស្សក្តី សហធម្មិកៈទាំង ៥ គឺ ភិក្ខុក្តី ភិក្ខុនីក្តី សាមណេរក្តី សាមណេរីក្តី សិក្ខមានាក្តី អ្នកទាំងអស់នេះ សមគួរជាទាយកធ្វើកឋិនទានបាន" សូមទានជ្រាប ៗ

១០.– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ត្រូវហើយ ចុះកំណើតកឋិនទាន លោកអ្នកណាជាទាយកធ្វើជាដំបូង ក្នុងកាលដែលព្រះអរិត្គន៍

ផន្ទាយុទៅបានធ្វើចំពោះព្រះសង្ឃក្នុងពេលនោះ? សូមលោកម្ចាស់សំដែងឲ្យជាក់ច្បាស់, ព្រោះរឿងនេះពុទ្ធបរិស័ទទាំងឡាយចង់ជ្រាបណាស់ នឹងបានយកជាទិដ្ឋានុគតិ តទៅខាងមុខទៀត ។

– បពិត្រព្រះមហាថេរដ៏ចំរើន! ឯកំណើតកឋិនទានដែលទាយកផ្តើមធ្វើជាដំបូងនោះគឺ "ព្រះបាទបសេនទិកោសល" ដូចមានរឿងដំណាលដោយសង្ខេបតទៅនេះ :–

កាលនោះព្រះបាទបសេនទិកោសល ព្រះអង្គបានតាក់តែងចាត់ចែងព្រះកឋិនទាន នាំទៅថ្វាយចំពោះព្រះភិក្ខុសង្ឃ មានអង្គព្រះកច្ចាយ-នត្ថេរជាប្រធាន ។ ព្រះកច្ចាយនត្ថេរទទួលគ្រង់តាមគន្លងកឋិនត្ថារកិច្ចសម្រេចសព្វប្រការ, គ្រាកាលនោះ ព្រះបរមសាស្តាចារ្យ ក៏ទ្រង់ត្រាស់ទេសនាសរសើរកុសលផលបុណ្យកឋិនទាន នៃព្រះបាទបសេនទិកោ-សលរាជ ដោយអនេកបរិយាយ ហើយទ្រង់ត្រាស់នាំអតីតនិទាននៃព្រះអង្គកាលអន្ទោលជាតិជា នរជីវទត្តបរមពោធិសត្វ បានជួយខ្វល់ខ្វាយចាត់ការកឋិនទាននៃនាយកុដុម្ពិក៏នាំថ្វាយព្រះបមមុនី គឺព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ព្រះអង្គទ្រង់ព្រោសប្រទានឲ្យព្រះសុជាតត្ថេរជាអគ្គសាវ័កនៃព្រះអង្គគ្រង់ក្នុងគ្រានោះ. ឯអង្គព្រះបរមសាស្តាជាម្ចាស់នៃយើងនេះ ព្រះអង្គក៏បានពុទ្ធព្យាករណ៍ទំនាយអំពីសំណាក់នៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈអំពីកាលនោះមក លុះព្រះអង្គបានត្រាស់ហើយ

ទើបទ្រង់សំដែងព្រះសទ្ធម្មវិសេសទេសនា ប្រារព្ធនូវបុព្វចរិយានៃព្រះអគ្គអំពីកាលព្រះអគ្គកើតជា នរជីវទុគ្គតពោធិសត្វ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធបទុមុត្តរៈមកនោះ ស្រេចហើយ ព្រះអគ្គទ្រង់អនុញ្ញាតសំពត់កឋិនដល់ភិក្ខុទាំងឡាយ ដែលមានត្រៃចីវរទុព្វលភាព ហើយទ្រង់បញ្ញត្តនូវសិក្ខាបទ ដែលព្រះសង្គីតិកាចារ្យបានពោលទុកក្នុងគម្ពីរមហាវគ្គដោយពិស្តារ ហើយទ្រង់ទេសនាសរសើរផលានិសង្សនៃកឋិនទាននេះថា មានផលវិសេសលើសលន់ពន់ប្រមាណណាស់ ។

លំដាប់នោះមានព្រះថេរៈ ១ ព្រះអង្គ ព្រះនាមនារទត្ថេរបានស្តាប់ព្រះធម៌ទេសនាកឋិនានិសង្សដូច្នោះហើយ ទើបលោកមានហឫទ័យជំពេញដោយបីតិជ្រះថ្លា គិតថា "កឋិនទានមានផលានិសង្សអស្ចារ្យយ៉ាងនេះ គួរអាត្មានឹងសាងថ្វាយដល់ជំនុំសង្ឃម្តងចុះ"; កាលព្រះនារទត្ថេរលោកគិតដូច្នោះហើយ ទើបលោកដោះទៀងទៅកាន់ត្រកូលញាតិ ហើយលោកបបួលពពួកញាតិលោកឲ្យជួយក្នុងការកឋិនទាន លុះបានគ្រប់គ្រឿងកឋិនហើយ លោកនាំអង្គព្រះកឋិននោះទៅកាន់អារាមមួយអន្លើដោយពពួកញាតិជាបរិវារ ។ លុះបានដល់អារាមហើយព្រះនារទត្ថេរក៏យកសំពត់កឋិននោះ ដម្កល់ទៀបព្រះបាទយុគលនៃព្រះតថាគត ហើយសូត្រវេរថ្វាយដោយបាលីថា ភន្តេ ឥមានិ ចីវរានិ ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស កឋិនត្ថាយ ទស្សាមិ ប្រែជាសេចក្តីថា

“បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាសូមថ្វាយនូវចីវរទាំងឡាយនេះដល់ព្រះភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធាន ដើម្បីក្រាលជាកឋិនក្នុងថ្ងៃនេះ” ។ គ្រាកាលនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គក៏ឲ្យប្រជុំភិក្ខុទាំងឡាយ ៩០០ រូប ហើយញុំាងភិក្ខុទាំងឡាយមានការដេរនូវចីវរកឋិនជាដើមឲ្យសម្រេចសព្វគ្រប់ប្រការ កាលនោះឯង ។ សាធុពៅ បពិត្រសាធុសប្បុរសទាំងឡាយ ! ឯកិរិយាដែលព្រះនាំទទេ្រធ្វើកឋិនដើម្បីភិក្ខុសង្ឃមានអង្គព្រះពុទ្ធជាប្រធាននោះ ក៏កើតជាអស្ចារ្យអស់ជំនុំសង្ឃសឹងនាំគ្នានិយាយសរសើរកុសលផលបុណ្យ នៃព្រះនាំទទេ្រជាអនេកបរិយាយ កាលនោះសម្តេចព្រះឈ្នះមារក៏ទ្រង់ត្រាស់ប្រកាសនាំនូវអតីតនិទាននៃព្រះអង្គ កាលកើតជាស្តេចបរមចក្កពត្រាធិរាជ ១ ព្រះអង្គទ្រង់ព្រះនាមព្រះបរមចក្រវិជិតរាជ ប្រកបដោយអំណាចជាធំក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ ព្រះអង្គបានសាងកឋិនទាន ថ្វាយព្រះពុទ្ធទ្រង់ព្រះនាមព្រះកោណ្ឌញ្ញសម្មាសម្ពុទ្ធដែលត្រាស់ដឹងក្នុងសារកប្បជាកប្បក្នុងយុគទៅហើយនោះ នាំមកសំដែងជាសណ្តាប់ប្រាប់ភិក្ខុទាំងឡាយ ក្នុងព្រះសាសនាដោយពិស្តារជាអនេកបរិយាយ ។ ក្នុងទីនេះអាត្មាភាពសំដែងសេចក្តីតែខ្លីៗ នាំមកឲ្យឃើញត្បុគ្គលអ្នកធ្វើ ព្រះបាទបសេនទិកោសលរាជជាបច្ចុប្បន្ននិទាន ព្រះនរជ័វទុត្តពោធិសត្វនិងនាយក្សត្រក៏នោះក្តី ស្តេចបរមចក្រវិជិតរាជនោះក្តី តីរនិទាននេះជា

អតីតនិទាន ចំណែកខាងព្រះសង្ឃអ្នកផ្ញើសេត គឺព្រះនារទត្ថេរជាបច្ចុប្បន្ននិទាន, និទានព្រះនារទត្ថេរផ្ញើកឋិននេះគួរយកជាបែបយ៉ាងបាន ហេតុនេះទើបឃើញបព្វជិតទាំងឡាយពីបុរាណផ្ញើកឋិនតៗមក ព្រោះតស្រ័យនិទានព្រះនារទត្ថេរនេះឯង; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាបាននាំនិទាន មកដោយសង្ខេបតែប៉ុណ្ណោះ សូមទានជ្រាប ។

១១– កល្លោសិ អនុត្តេរៈ ម្នាលអនុត្តេរ! លោកម្ចាស់ធ្វើវត្តាសពង់ពិតមែន បេះទាញនិទាននាំមកសំដែងប្រៀបប្រាយអធិប្បាយស្ដាប់បានដោយងាយ ល្មមត្រូវបរិស័ទទាំងឡាយសន្និដ្ឋានចូលចិត្តយកជាបែបយ៉ាងបានហើយ, លំដាប់តពីនេះទៅខ្ញុំលើកយកប្រស្នាដទៃមកសួរតទៅទៀត ៗ អើលោកម្ចាស់ កាលបើទាយកដង្ហែកឋិនចូលមកវេរចំពោះព្រះសង្ឃហើយ តើសង្ឃត្រូវទទួលដោយអាការដូចម្ដេច? សូមលោកម្ចាស់វិសជ្ជនាមក ហើយអាងគម្ពីរផង ដើម្បីជាគោលចារិកចាំមួនតទៅ ។

(មានត)

កាបំនកាថា

របៀបទេសនា បុច្ឆា-វិសជ្ជនា

# ព្រះមហាឧត្តមវិជ្ជា កែ-អឿន វីរិយប្បញ្ញោ

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ព្រះទេពសត្ថា សួរ-ហាយ ពិនិត្យកែសម្រួល

(តមក)

---

— ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! រឿងនេះបើតាមគម្ពីរវិនយាលង្ការដីកា លោកថែថា បដិគ្គហណកិច្ចំ នត្ថិ ទាយកេន ចីវរេ ទិន្នេ សង្ឃស្ស ចិត្តេន សម្បដិច្ឆនមត្តមេវ បមាណំ ហោតិ កិច្ចដែលត្រូវទទួល (ដោយកាយ ឬដោយវាចា) មិនមានទេ កាលបើទាយកវេរប្រគេនចីវរមក យកតែត្រឹមការទទួលដោយចិត្តរបស់សង្ឃប៉ុណ្ណោះជាប្រមាណ; ឯវំ តុណ្ហីភាវេន សម្បដិច្ឆនមត្តមេវ ហោតិ កាលបើដូច្នេះ ការទទួលគឺគ្រាន់តែទទួលដោយតុណ្ហីភាពក៏បានហើយ ។ បពិត្រព្រះមហាថេរ! ការទទួលសំពត់កឋិនរបស់សង្ឃ ដោយន័យដូចបានវិសជ្ជនាមកនេះ សូមទានប្រាប ។

១២– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះ ត្រឹមត្រូវតាមគម្ពីរដីកាហើយ ខ្ញុំនឹងសួរតទៅទៀត ។

អើអនុត្រេ! មានពាក្យខ្លះគេនិយាយថាបួសជាលោកសង្ឃហើយ មិនត្រូវខ្វល់ខ្វាយប្រៀបប្រាយឲ្យគេធ្វើកប្បិនទានចំពោះខ្លួនទេ ត្រូវតែឧបាសក ឧបាសិកាធ្វើដោយសទ្ធាចិត្តគេទើបគួរ តើពាក្យដែលគេថានេះគួរស្តាប់យកជាទិដ្ឋានុគតិបានដែរឬទេ សូមលោកម្ចាស់សំដែងសេចក្តីនេះញែកឲ្យស្រឡះទៅមើល ។

ភន្តេ ថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! ពាក្យដែលគេថានោះក៏គួរស្តាប់គួរយកខ្លះ ព្រោះព្រះសម្មាសម្ពុទ្ធបានទ្រង់ប្រកាសហាមក្ខុង៍អនេត្តកា-ការ ២៤ ប្រការ មានក្ខុង៍កប្បិនក្ខនកៈឯណោះដោយពិត គឺសេចក្តីថា និមិត្តកពេទ្យ ភិក្ខុឯណាធ្វើនិមិត្តប្រៀបប្រាយនិយាយរកទាយកថា សំពត់នេះសាច់ក្រាស់សាច់ល្អិតល្អ ធ្វើកប្បិនបាន ហើយទាយកនោះនាំមកថ្វាយ យ៉ាងនេះក្រាលមិនឡើងជាកប្បិនប្រការ ១ - បរិកថាកពេទ្យ ភិក្ខុឯណាក្លែងនិយាយបរិយាយអានិសង្សកប្បិន ហើយឃោសនាឲ្យកប្បិនកើតឡើង យ៉ាងនេះក្រាលមិនឡើងប្រការ ១ តាវកាលិកពេទ្យ ភិក្ខុទៅខ្ចីសំពត់គេយកមកក្រាលកប្បិន យ៉ាងនេះមិនឡើងជាកប្បិនប្រការ ១ មួយទៀតបើភិក្ខុសាមណេរទៅឃោសនាសូមទាយកមិនមែនជាញាតិ មិនមែនជាបវារណា យ៉ាងនេះក្រាលមិនឡើងជាកប្បិនប្រការ ១ បើភិក្ខុទៅឃោសនាសូមសំពត់អំពីញាតិ មានមាតាបិតាខ្លួនជាដើម ទោះឲ្យកើតជាកប្បិនឡើងក៏ក្តី ទឹងមានទោសដោយវិញ្ញត្តិសិក្ខាបទនោះឥតអង្គមាន តែថា

មិនគួរផល់កឋិន ព្រោះថាកឋិននេះកើតឯង ដូចសំពត់ទិព្វកោសេយ្យព្រស្តអណ្តែតត្រសែតធ្លាក់ពីកណ្តាលអាកាស មកក្នុងកណ្តាលជំនុំសង្ឃគួរដោយពុទ្ធានុញ្ញាត មួយទៀតភិក្ខុទៅសូមចីវរអំពីញាតិមានមាតាបិតាជាដើម ហើយទើបឲ្យកើតជាកឋិន ឃើញថាគួរផល់សង្ឃអាវាសជាមួយគ្នាក្តី ឬឲ្យសង្ឃក្នុងអាវាសដទៃក្តី សេចក្តីនេះនឹងមានបទហាមក៏ទេ តែភិក្ខុនោះអាចការពារអាបត្តិ ៥ ប្រការ ក៏ផតអត្ថមាន បានតែអានិសង្សក្នុងបរលោកប៉ុណ្ណោះឯង; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាវិសជ្ជនាមកដោយសេចក្តីសង្ខេបតែប៉ុណ្ណោះ សូមទានព្រាប ។

១៣– សាធុ សាធុ អនុរុទ្ធ: ម្នាលអនុរុទ្ធ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកត្រូវពិតប្រាកដហើយ តែបើតាមគំនិតរបស់ខ្ញុំយល់ឃើញថា ធ្វើជាអ្នកបួសហើយ មិនត្រូវមានកង្វល់នឹងធ្វើអាមិសទានទៀតទេ ដូចយ៉ាងកឋិនទាននេះ ក៏ចប់បញ្ចូលក្នុងអាមិសទានដែរ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងមហាបរិនិព្វានសូត្រថា "ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយកុំខ្វល់ខ្វាយនឹងអាមិសបូជាឡើយ ត្រូវអ្នកទំព្រឹងប្រែងក្នុងបដិបត្តិបូជា គឺសេចក្តីប្រតិបត្តិក្នុងសីល - សមាធិ - បញ្ញាឲ្យជាប្រយោជន៍របស់ខ្លួនចុះ ឯអាមិសបូជាឬអាមិសទានទុកមុខងារឲ្យគ្រហស្ថគេធ្វើចុះ" ខ្ញុំបានឃើញព្រះពុទ្ធឱវាទនេះហើយ បានជាយល់ថា អ្នកបួសមិនត្រូវរវល់នឹងអាមិសទានឬអាមិសបូជាឡើយ; អើអនុរុទ្ធ! រឿងនេះ អ្នកយល់ឃើញដូចម្តេចទៅវិញ? សូមអ្នកវិសជ្ជនាមកមើល! ។

– កិញ្ចាបិ មហាថេរៈ បពិត្រព្រះមហាថេរ! រឿងដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងមហាបរិនិព្វានសូត្រ ក៏មែនពិតហើយ តែរឿងនេះដោយព្រះសម្ពុទ្ធថ្លែងទៅអនាគតកាល ពួកបព្វជិតអ្នកបួសទាំងឡាយមិនយកចិត្តទុកដាក់ក្នុងបដិបត្តិបូជា ដឹកនាំគ្រហស្ថទាំងឡាយឲ្យធ្វើតែអាមិសបូជា ដើរអង្គាសឃោសនាទាយកទាយិកាធ្វើតែអាមិសបូជា អំពើនេះមិនអាចញុំាងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿង សូម្បីតែ ១ អង្គុលីឡើយ ព្រោះហេតុនោះហើយបានជាទ្រង់សំដែងឃាត់បព្វជិតមិនឲ្យខ្វល់ខ្វាយក្នុងអាមិសបូជា ឲ្យខំខ្វល់ខ្វាយតែក្នុងបដិបត្តិបូជា ទើបអាចញុំាងព្រះពុទ្ធសាសនាឲ្យចំរើនរុងរឿង អស់កាលជាអង្វែងទៅ ។

ម្យ៉ាងទៀតអ្នកបួសដែលគ្មានកង្វល់នឹងកឋិនទាន មកពីគ្មានរបស់អ្វីនឹងធ្វើ ឬគ្មានសទ្ធានឹងគ្មានទំនងត្រូវធ្វើ បើមានលាភសក្ការៈដែលកើតឡើង ឬបានមកដោយធម៌ គួរតែធ្វើ ព្រោះកឋិនទាននេះព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យសហធម្មិកទាំង ៥ គឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ធ្វើបាន ព្រោះការបរិច្ចាគទាន បានឈ្មោះថាជាកិច្ចលះមច្ឆរិយៈដែលជាកិលេសត្រូវតែលះ បុគ្គលដែលមានភាពជាបុថុជ្ជននៅឡើយ ឈ្មោះថានៅក្នុងអំណាចភ្លើង គឺរាគៈ ទោសៈ មោហៈ នឹងមច្ឆរិយធម៌ជាដើម តែងដុតរោលរាលជាធម្មតា, សមតាមធម្មទេសនាដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងក្នុងអាទិត្តសូត្រថា

អាទិត្តស្មឹ អគារស្មឹ    យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ    នោ ច យំ តត្ថ ឌយ្ហតិ,
ឯវមាទិត្តកោ លោកោ    ជរាយ មរណេន ច
នីហរេថេវ ទានេន    ទិន្នំ ហោតិ សុនីភតំ ។

សេចក្តីថា: "កាលបើផ្ទះត្រូវភ្លើងឆាបឆេះ ជនម្ចាស់ផ្ទះតែងជញ្ជូនទ្រព្យសម្បត្តិ មានភាជនៈ (ជាដើម) ចេញអំពីផ្ទះ, ទ្រព្យណាដែលគេជញ្ជូនចេញផុត ភ្លើងនេះមិនបាន ទ្រព្យនោះរមែងបានទៅជាប្រយោជន៍របស់គេតទៅ យ៉ាងណាមិញ សត្វលោកដែលត្រូវភ្លើងគឺជរានិងមរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនចេញឲ្យផុតអំពីផ្ទះគឺកាយដោយការឲ្យទាន ព្រោះថាទានដែលគេឲ្យហើយនោះឯង ឈ្មោះថាបានជញ្ជូនទុកដោយល្អ មិនឲ្យភ្លើងឆេះបាន ក៏យ៉ាងនោះដែរ"; បពិត្រព្រះមហាថេរដ៏ចំរើន! ខ្ញុំព្រះករុណាបានវិសជ្ជនាមកអំពីរឿងនេះ អស់សេចក្តីតែប៉ុណ្ណេះ សូមទានជ្រាប ។

១៤– កល្យាសិ អនុត្តរៈ ម្នាលអនុត្តរ! លោកម្ចាស់ប៉ិនប្រសប់ពែន ចេះវិសជ្ជនាមកស្តាប់បានដោយងាយ ខ្ញុំនឹងលើកប្រស្នាដទៃសួរតទៅទៀត ។ អើលោកម្ចាស់! ចុះទាយកម្ចាស់កឋិនទាន ធ្វើដូចម្តេចទើបទៅជាសម្បទាន? បើត្រូវការវេរបស់ផ្សេងៗ ចំពោះភិក្ខុអ្នកទទួល

ក្រាលកឋិនដោយខ្សែកផង តើត្រូវប្រតិបត្តិដូចម្ដេច? សូមលោកម្ចាស់និមន្តអធិប្បាយឲ្យសព្វគ្រប់មកមើល ។

— បពិត្រព្រះមហាថេរ! សំពត់សម្រាប់ក្រាលកឋិន ជារបស់ពប់បញ្ចូលក្នុងសង្ឃទាន ត្រូវវេរតាមបាលីដែលធ្លាប់វេរថា ឥមំ ទុស្សំ កឋិនចីវរំ ភិក្ខុសង្ឃស្ស ទេម ។ ទុតិយម្បិ, តតិយម្បិ ។ «យើងខ្ញុំទាំងឡាយសូមវេរនូវសំពត់នេះ ជាចីវរដើម្បីកឋិនចំពោះភិក្ខុ-សង្ឃ ។ អស់វារៈពីរដងផង, អស់វារៈបីដងផង» ។ ឯគ្រឿងបរិក្ខារសម្រាប់ប្រគេនចំពោះលោកអ្នកក្រាលកឋិនតែ ១ រូបនោះ ឲ្យវេរថា យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសង្សានិ តស្សេវ ទេម ។ ទុតិយម្បិ, តតិយម្បិ ។ «កឋិនរបស់យើងខ្ញុំទាំងឡាយ ដែលលោកម្ចាស់អង្គណាកាន់យកហើយ យើងខ្ញុំទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារកឋិនទាំងឡាយនេះ ប្រគេនលោកម្ចាស់នោះឯង ។ អស់វារៈពីរដងផង, អស់វារៈបីដងផង» ។ តែក្នុងអដ្ឋកថា អធិប្បាយថា បើតា-យកវេរថា «យេនម្ហាកំ ។ល។ តស្សេវ ទេម» យ៉ាងនេះហើយ សង្ឃមិនជាឥស្សរៈធំលើបរិក្ខារទាំងនោះទេ ព្រោះហេតុនោះបើតាយកចង់បានផលានិសង្សច្រើន ត្រូវវេរឲ្យជារបស់សង្ឃ គួរវេរដោយខ្សែកតាមបាលីដែលធ្លាប់វេររៀងៗមក ឬនឹងវេរឲ្យខ្លីដោយមិនបាច់រៀបរាប់ឈ្មោះរបស់គ្រប់មុខ គ្រាន់តែថារបស់នេះៗ យ៉ាងនេះក៏គួរដូចបាលីថា

ឥមានិ មយំ ភន្តេ វត្ថនិ ភិក្ខុសង្ឃស្ស និយ្យាទេម ។

«បពិត្រលោកម្ចាស់ដ៏ចំរើន! យើងខ្ញុំទាំងឡាយសូមវេរនូវរបស់ទាំងឡាយនេះចំពោះព្រះភិក្ខុសង្ឃ» ។ បើវេរយ៉ាងនេះទើបរបស់ទាំងនោះមានអំណាចចូលទៅដល់សង្ឃទាំងអស់ ទាំងភាគិសង្ឃរបស់ទាយកជាម្ចាស់ទានក៏បានច្រើន, បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាបានវិសជ្ជនាមកអំពីប្រស្នានេះអស់សេចក្តីតែប៉ុណ្ណោះ សូមទានជ្រាប ។

១៥– សាធុ សាធុ សុន្ទរំ ខោ អនុត្តរ: ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកត្រឹមត្រូវល្អហើយ, បពិត្រសប្បុរសទាំងពួង! បើលោកអ្នកមានសេចក្តីគាប់ចិត្តបែបណា គប្បីប្រព្រឹត្តតាមកាន់យកបែបនោះចុះ ព្រោះលោកម្ចាស់អនុត្តរដែលវិសជ្ជនាមក តាមតែច្បាប់ដែលមានមកក្នុងអដ្ឋកថាកឋិនក្ខន្ធកៈប៉ុណ្ណោះឯង; ឥតោ បរំ បន្ទាប់អំពីនេះទៅខ្ញុំនឹងសួរលោកម្ចាស់តទៅទៀត ។ អើអនុត្តរ! ចុះកាលបើទាយកវេរសំពត់កឋិនដល់សង្ឃរួចហើយ តើដំនុំសង្ឃត្រូវប្រគល់សំពត់កឋិនឲ្យទៅភិក្ខុអ្នកក្រាលដោយវិធីដូចម្តេចទៅ? ។

(មានត)

# កឋិនកថា

របៀបទេសនាបុច្ឆា - វិសជ្ជនា

## ព្រះមហាឧត្តមវិជ្ជា កែ - អឿន (វីរិយបញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង

## ព្រះទេពសត្ថា ស៊ួរ-ហាយ ពិនិត្យកែសម្រួល

(តមក)

— ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! តាមគម្ពីរវិនយាលង្ការដីកា បង្គាប់ថា ញត្តិទុតិយកម្មវាចាយ ទាតព្វំ "ត្រូវសង្ឃប្រគល់ឲ្យដោយញត្តិទុតិយកម្មវាចា" ។ ឯញត្តិទុតិយកម្មវាចា ជាវាចាប្រគល់សំពត់កឋិនតាមពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គ ដែលភិក្ខុសង្ឃតែងសូត្ររៀងរាល់តែកឋិនទាននោះឯង សូមបានជ្រាប ។

១៦– ម្នាលអនុគ្គេរ! ខ្ញុំយល់ហើយ, ចុះបើសង្ឃប្រគល់សំពត់កឋិនឲ្យយ៉ាងនេះហើយ ត្រូវឲ្យភិក្ខុអ្នកក្រាលប្រតិបត្តិដូចម្ដេច? ។

— ភន្តេ ថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! តាមគម្ពីរបរិវារៈបង្គាប់ថា តេន កឋិនត្ថារកេន ភិក្ខុនា តទហេវ ធោវិត្វា វិមជ្ជិត្វា វិចារេត្វា ឆិន្ទិត្វា សិព្វេត្វា រជិត្វា កប្បំ កត្វា កឋិនំ អត្ថរិតព្វំ "ត្រូវឲ្យភិក្ខុអ្នកក្រាលកឋិននោះ បោក គក់ ប្រចាប់ វាស់កាត់ ដេរ ជ្រលក់ ធ្វើកប្បពិន្ទុឲ្យហើយស្រេចក្នុងថ្ងៃនោះ ហើយក្រាលកឋិន

ទៅចុះ"; តែធ្វើឲ្យគន្លងថ្ងៃនោះទៅ ក្រាលកឋិនមិនកើតឡើយ ៗ បពិត្រព្រះថេរៈ! ខ្ញុំព្រះករុណាវិសជ្ជនាមកបានសេចក្ដីប៉ុណ្ណេះ សូមក្រាប ៗ

១៧– សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោកម្ចាស់ឆ្លើយមកនេះ ត្រូវពិតហើយ; ចុះបើចីវរកឋិននោះទាយកជាសាមីទានគេធ្វើបរិកម្មសម្រេចជា ស្បង់-ចីពរ-សង្ឃាដី រួចស្រេចស្រាប់មកហើយ, គេវេរប្រគេនដល់សង្ឃតែម្ដង តើសង្ឃត្រូវប្រតិបត្តិដូចម្ដេច? លោកម្ចាស់ ៗ

– បពិត្រព្រះមហាថេរ! បើតាមគម្ពីរកង្ខាវិតរណីអដ្ឋកថានិងគម្ពីរវជីរពុទ្ធដីកា ពោលសរសេរថា កតបុព្វករណមេវ ឧប្បជ្ជតិ លុទ្ធមេវ បើចីវរដែលទាយកធ្វើបុព្វករណៈរួចហើយ កើតឡើងដល់សង្ឃជាការប្រពៃណាស់ហើយ ដោយហេតុគ្រហស្ថជាអ្នកឈ្លាសវៃក្នុងការកាត់ដេរជ្រលក់ចីវរ ត្រូវសង្ឃទទួលហើយប្រគល់ឲ្យទៅភិក្ខុអ្នកក្រាលដោយកម្មវាចាចុះ មិនបាច់ធ្វើបរិកម្មទៀតទេ ប្រៀបដូចកុលបុត្រដែលមានកេសាកោរស្រេចហើយត្រូវបំបួសឲ្យទៅចុះ ឯភិក្ខុអ្នកក្រាលកឋិននោះសោតត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះ រួចហើយត្រូវញុំាងសង្ឃឲ្យអនុមោទនាតែម្ដងទៅ ព្រោះមិនមានកិច្ចនឹងត្រូវធ្វើបុព្វ-ករណៈ ដែលគេធ្វើត្រឹមត្រូវទាំងកាត់ដេរជ្រលក់រួចមកហើយនោះម្ដងទៀតទេ, កាលបើសង្ឃប្រគល់ចីវរកឋិនដែលសម្រេចស្រាប់មកឲ្យយ៉ាង

នេះហើយ បើភិក្ខុអ្នកក្រាលកឋិន ត្រូវការក្រាលដោយសង្ឃាដី ត្រូវបច្ចុទ្ធរ៍ដកសង្ឃាដីចាស់ចេញ អធិដ្ឋានសង្ឃាដីថ្មីឡើង រួចហើយត្រូវបញ្ចេញវចីភេទក្រាលចុះ, បើត្រូវការក្រាលដោយស្បង់ឬចីពរ ក៏ត្រូវធ្វើដូចគ្នានឹងសង្ឃាដីចុះ; បពិត្រព្រះមហាថេរ! ខ្ញុំព្រះករុណាវិសជ្ជនាមក បានសេចក្តីយ៉ាងនេះ សូមទានជ្រាប ។

១៨ – សាធុ សាធុ អនុត្តេរៈ ម្នាលអនុត្តេរ! ប្រស្នាដែលលោកម្ចាស់វិសជ្ជនាមក ក៏ឃើញថាត្រឹមត្រូវពិតប្រាកដដូច្នោះមែនពិតហើយ ។ សាធុពរ បពិត្រសាធុសប្បុរសទាំងឡាយ! លោកអ្នកគប្បីសន្និដ្ឋានចូលចិត្តជឿឲ្យស៊ប់ក្នុងគម្ពីរទាំងពីរ ដែលលោកម្ចាស់អនុត្តេរបានពោលមកហើយនោះចុះ ឥតមានខុសឃ្លៀងឃ្លាតឡើយ ។ ឥតោ បរំ ដទៃអំពីនេះទៅ ខ្ញុំនឹងលើកយកអានិសង្សទានទាយក អ្នកធ្វើចីវរទានមកសួរលោកម្ចាស់វិញទៀត ។ តើលោកម្ចាស់ ចំណែកទាយកអ្នកធ្វើចីវរទានតើនឹងបានអានិសង្សយ៉ាងណាទៅ? សូមលោកម្ចាស់និមន្តលើកយករឿងនិទានណាមួយ ដែលមានសំដែងក្នុងគម្ពីរមកសំដែងកែខសេចក្តីដើម្បីអស់លោកអ្នកពុទ្ធបរិស័ទ បានជ្រាបច្បាស់ផងមើល ។

ភន្តេ មហាថេរៈ បពិត្រព្រះគុណម្ចាស់ដ៏ចំរើន! បុគ្គលដែលប្រកបដោយសទ្ធា បានធ្វើចីវរទាន រមែងបានអានិសង្សប្រយោជន៍នឹងសេចក្តីសុខជាច្រើន ដូចមានវត្ថុនិទានសំដែងថា អតីតេ ពារាណសីវាសី

ឯកោ កុដុម្ពិកោ ក្នុងកាលដ៏កន្លងទៅហើយ មានកុដុម្ពីកម្នាក់នៅក្នុងនគរពារាណសី មានកាលថ្ងៃមួយ ត្រេចដើរទៅក្នុងព្រៃ បានជួបនឹងព្រះបច្ចេកពុទ្ធមួយព្រះអង្គកំពុងដេរចីវរ ដែលខ្វះសំពត់មិនទាន់គ្រប់គ្រាន់ត្រង់អនុវាតបណ្ដោយ កុដុម្ពីកនោះក៏មានចិត្តជ្រះថ្លា ហើយយកសំពត់សម្រាប់បង្កិរបស់ខ្លួនប្រគេនទៅព្រះបច្ចេកពុទ្ធ ។ ដោយអានុភាពនៃបុញ្ញកម្មនេះ បុរសនោះក៏បានទៅកើតក្នុងស្ថានតាវត្តិង្សទេវលោកបានសោយទិព្វសម្បត្តិជាយូរអង្វែង លុះច្យុតអំពីទេវលោកនោះមកក៏បានមកកើតក្នុងត្រកូលអាមាត្យនៅក្នុងទីចម្ងាយ ១ យោជន៍អំពីនគរពារាណ-សី ។ បុរសនោះមានវ័យវឌ្ឍនាការចំរើនធំឡើង ។ មានកាលមួយថ្ងៃជាថ្ងៃលេងនក្ខត្តឫក្ស បុរសនោះនិយាយនឹងមាតារបស់ខ្លួនថា “បពិត្រអ្នកម៉ែ! ចូរអ្នកឲ្យសំពត់ ១ មកខ្ញុំ ៗ នឹងទៅលេងនក្ខត្តឫក្សនឹងគេ” ។ មាតានោះក៏ឲ្យសំពត់ស្អាត ១ ទៅ ។ បុរសនោះនិយាយថា “សំពត់នេះមានសាច់គ្រោតគ្រាតណាស់ ខ្ញុំមិនយកទេ” ។ មាតាក៏ឲ្យសំពត់ដទៃទៀត បុរសនោះក៏មិនព្រមយកសំពត់នោះទៀត បាននិយាយនឹងមាតាថា “បើអ្នកម្ដាយរកសំពត់សាច់ម៉ដ្ឋឲ្យខ្ញុំមិនបានទេ ខ្ញុំនឹងទៅស្វែងរកសំពត់គួរជាទីគាប់ចិត្តឲ្យបាន” ។ មាតានិយាយថា ‘ម្នាលកូន! មាតាមិនស្គប់កូនទេ សព្វថ្ងៃនេះម្ដាយចង់ឲ្យកូនឯងបានសោយរាជ្យក្នុងនគរពារាណសីនេះផង’ ។ បុរសនោះក៏ថ្វាយបង្គំលាមាតាដើរចេញទៅ ។

-ហេតុតែកុសលកម្មអំពីបុព្វជាតិត្រូវអំណោយផល បុរសនោះដើរចូលទៅកាន់នគរពារាណសី ហើយចូលទៅដេកទទូរលើផែនថ្មមង្គលសិលាក្នុងសួនឧទ្យាន ។ កាលនោះជាថ្ងៃព្រះរាជាក្នុងនគរពារាណសីទ្រង់សោយព្រះទិវង្គតទៅបាន ៧ ថ្ងៃហើយ ។ ពួកជនមានអាមាត្យជាដើម នាំគ្នាធ្វើសរីរកិច្ចនៃព្រះរាជាជាស្រេច រួចប្រឹក្សាគ្នាថា "ឥឡូវព្រះរាជាមានតែព្រះរាជធីតា ឯព្រះរាជបុត្រមិនមានឡើយ ធម្មតាស្រុកនគរបើឥតមានស្តេច នឹងមិនបានស្ថិតស្ថេរយូរឡើយ នឹងត្រូវវិនាសជាប្រាកដ" ហើយក៏រៀបចំបុស្សរថ ទឹមសេះសិន្ធព ៤ មានពណ៌សម្បុរដូចផ្កាកុមុទ ហើយយករាជកកុធភណ្ឌទាំង ៥ ប្រការដាក់លើរថ រួចលែងបុស្សរថទៅ ។ បុស្សរថនោះក៏ចេញទៅតាមទិសខាងកើត ហើយចូលទៅកាន់សួនឧទ្យាន ប្រទក្សិណកុមារដែលដេកទទូរក្នុងទីនោះហើយឈប់នៅស្ងៀមធ្វើអាការហាក់ដូចជាប្រុងប្រៀបខ្លួនឲ្យកុមារឡើងជិះ ។ បុរោហិតក៏បើកជាយសំពត់ឡើងមើលឃើញផ្ទៃបាតជើងសព្វគ្រប់ ហើយទាយថា "បុរសនេះគួរនឹងសោយរាជ្យបាន" ហើយក៏ប្រគំតូរ្យតន្ត្រីអស់វារៈ ៣ ដង ។ លំដាប់នោះកុមារភ្ញាក់ខ្លួនបើកភក្ត្រឡើងសួរថា "អ្នកទាំងឡាយនាំគ្នាមករកអ្វី?" ។ ជនទាំងឡាយតបថា "បពិត្រព្រះសម្មតិទេព! ឥឡូវរាជសម្បត្តិធ្លាក់លើព្រះអង្គហើយ" ។

(មានត)

## កាបិឆកថា

*របៀបទេសនា បុច្ឆា-វិសជ្ជនា*

# ព្រះមហាឧត្តមវិជ្ជា កែ-អឿន វីរិយបញ្ញោ

*វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង*

## ព្រះទេពសត្ថា សួរ-ហាយ ពិនិត្យកែសម្រួល

(តចប់)

---

កុមារសួរថា "ព្រះពរជារបស់អ្នកទាំងឡាយទៅណា?" ។ – ព្រះពរជារបស់យើងខ្ញុំទាំងឡាយទ្រង់សោយទិវង្គតទៅហើយ ។ – សោយទិវង្គតទៅប៉ុន្មានថ្ងៃហើយ? ។ – មកដល់ថ្ងៃនេះ ៧ ថ្ងៃហើយ ។ – ចុះព្រះរាជបុត្រក្តី ព្រះរាជធីតាក្តីមិនមានទេឬ? ។ – មានតែព្រះរាជធីតា ព្រះរាជបុត្រពុំមានទេ ។ កុមារឆ្លើយថា "បើដូច្នោះយើងនឹងសោយ-រាជ្យ" ។ ជនទាំងនោះក៏ធ្វើមណ្ឌបសម្រាប់អភិសេក ១ រំពេច ហើយរៀបចំអភិសេកក្នុងមណ្ឌបនោះ ថ្វាយព្រះនាមជា ព្រះបាទឥន្ទរាជ ហើយនាំយកសំពត់មានដំឡៃ ១ ពាន់កហាបណៈទៅថ្វាយ ។ គ្រានោះ ព្រះរាជាមានព្រះបន្ទូលថា "សំពត់នេះជាសំពត់មានសាច់គ្រោតគ្រាតណាស់ យើងមិនត្រូវការទេ អ្នកទាំងឡាយចូរយកកុណ្ឌីមាសមក យើងមុខជានឹងបានសំពត់ល្អ" ហើយក៏ក្រោកឡើងយកព្រះហស្តកាន់កុណ្ឌីបាចសាចទឹកទៅក្នុងទិសខាងកើត ។ ដើមកល្បព្រឹក្ស៨

ដើមក៏ទំលាយផែនដីគាន់ផុសឡើងភ្លាម, ទិសខាងត្បូងក្តី ខាងលិចក្តី ខាងជើងក្តី មានដើមកល្បព្រឹក្ស ៨ ដើមៗ ផុសឡើងដូចគ្នា ៗ រួមជាដើមកល្បព្រឹក្ស ៣២ ដើម ផុសឡើងដោយប្រការដូច្នេះ ៗ សំពត់ក៏កើតឡើងបរិបូណ៌ក្នុងដើមកល្បព្រឹក្សទាំងអម្បាលនោះ ៗ ព្រះរាជានោះទ្រង់ស្លៀកសំពត់ទិព្វ ១ ដណ្តប់សំពត់ទិព្វ ១ ទ្រង់ឲ្យទូងស្គរកេរ៏ប្រកាសប្រាប់មនុស្សទាំងអស់នៅក្នុងដែនថា "ពួកស្រឹកក្នុងដែនព្រះបាទនន្ទរាជ កុំបាច់វៃស្រូវត្រែអម្បោះឡើយ" ហើយទ្រង់ឲ្យលើកឆត្រឡើង ទ្រង់គង់លើដំរីដ៏ប្រសើរ យាងចូលទៅកាន់ព្រះនគរ ទ្រង់ឡើងកាន់ប្រាសាទសោយសម្បត្តិដ៏ថ្កុំថ្កើង ទ្រង់រៀបចំដែនទាំងមូលឲ្យស្អាតល្អប្រហែលនឹងឧត្តរកុរុទ្វីប ទ្រង់ព្រះរាជទានសំពត់ទិព្វដល់ពួកមនុស្សដែលមកទាំងអម្បាលម៉ាន ៗ លុះកាលជាចំណេរខាងក្រោយមកទ្រង់មានសេចក្តីនឿយណាយក្នុងឃរាវាស ហើយទ្រង់ព្រះផ្នួសជាមួយនឹងនាងទេវីជាអគ្គមហេសី ទ្រង់គង់នៅក្នុងឧទ្យាន បានឈានសមាបត្តិមានសភាពជាបុគ្គលមិនបានសាបសូន្យចាកឈាន លុះអស់ព្រះជន្មាយុទៅ ក៏បានទៅកើតក្នុងព្រហ្មលោក ៗ ព្រះបាទនន្ទរាជនោះគឺព្រះមហាកស្សបត្ថេរក្នុងកាលឥឡូវនេះ, នាងទេវីគឺនាងភទ្ទាកាបិលានី ជាករិយាព្រះថេរៈក្នុងកាលនៅជាគ្រហស្ថ ៗ រឿងព្រះបាទនន្ទរាជនេះមានមកក្នុងអដ្ឋកថាសំសារមោចកបេតវត្ថុ; កន្ត មហាថេរៈ បតិត្រព្រះ

មហាថេរដ៏ចំរើន! ខ្ញុំព្រះករុណាបាននាំរឿងនេះមកសំដែង ដើម្បីឲ្យឃើញជាគួយ៉ាងថា អ្នកដែលបានធ្វើចីវរទាន មានអានិសង្សដូចបានវិសជ្ជនាមកនេះ សូមទានជ្រាប ៗ

១៩ – សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! អានិសង្សចីវរទានដែលលោកវិសជ្ជនាមក ព្រមទាំងទាញរឿងនិទានមកសំដែងជាគួយ៉ាងឃើញថាពីរោះគ្រាះគ្រាយ ល្មមលោកអ្នកសប្បុរសទាំងឡាយ សន្និដ្ឋានចូលចិត្តយកជាបែបយ៉ាងបានហើយ ៗ តពីនេះទៅខ្ញុំនឹងសួរលោកតទៅទៀត ៗ អើលោក! ចីវរទាន ឃើញថាមានអានិសង្សជាអស្ចារ្យមែនហើយ ចុះអានិសង្សនៃចីវរទាន ដែលស្ត្រីបុរសបានធ្វើហើយ គេនឹងបានសម្រេចយ៉ាងណាទៅទៀត? សូមលោកនិមន្តសំដែងញែកចែកឲ្យស្រឡះពីគ្នា ដើម្បីលោកអ្នកទាំងឡាយបានជ្រាបផងមើល ៗ

– ភន្តេ មហាថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! ឯអានិសង្សចីវរទានយ៉ាងខ្ពស់របស់ស្ត្រីបុរសដែលបានធ្វើហើយ បើតាមគម្ពីរធម្មបទ-ខុទ្ទកនិកាយ បុប្ផវគ្គវណ្ណនា លោកសំដែងថា ឥត្ថីនំ ហិ ចីវរទានំ មហាលតាបសាធនេន មត្ថកំ បប្បោតិ បុរិសានំ ឥទ្ធិមយបត្តចីវរេនាតិ សេចក្តីថា "ចីវរទាននៃស្ត្រីទាំងឡាយរមែងបានប្រដាប់ដោយគ្រឿងមហាលតាបសាធនៈ គួយ៉ាងដូចនាងវិសាខាមហាឧបាសិកា នាងបានប្រដាប់ដោយគ្រឿងមហាលតាបសាធនៈនេះ ដោយផលា-

និសង្សដែលនាងបានថ្វាយចីវរសាដក អំពោះ បេស ទឹងទឹកដ្រែលក់ផល ភិក្ខុសង្ឃ ២០ ពាន់អង្គ គង់សាសនានៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈឯណោះ ឯគ្រឿងប្រដាប់នាងនោះដំឡៃ ៩ កោដិ ឈ្នួលជាងដែលធ្វើមួយសែន, ចីវរទានខាងបុរសទាំងឡាយវិញ ទឹងបានសម្រេចដោយបាត្រចីវរប្រកបដោយបុញ្ញឫទ្ធិ គឺថាបុរសនោះបានជួបប្រទះព្រះសម្មាសម្ពុទ្ធអង្គណាមួយ មានប្រាថ្នាទឹងបួសមិនបាច់ស្វែងរកបាត្រត្រៃចីវរអំពីណាឡើយ គ្រាន់តែព្រះអង្គត្រាស់ថា “ឯហិ ភិក្ខុ អ្នកឯងចូរជាភិក្ខុទៅចុះ” បានសម្រេចទៅជាភិក្ខុ ១ រំពេច; ភន្តេ ថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន! អានិសង្សចីវរទានយ៉ាងខ្ពស់បំផុតរបស់ស្ត្រីបុរសដែលបានធ្វើចីវរទានដល់សង្ឃ ដូចខ្ញុំព្រះករុណាបានវិសជ្ជនាមកនេះ សូមទានជ្រាប ។

២០ - សាធុ សាធុ អនុត្តរៈ ម្នាលអនុត្តរ! ប្រស្នាដែលលោកសំដែងមក ឃើញថាពីរោះអស្ចារ្យណាស់, លោកអ្នកសប្បុរសទាំងឡាយគប្បីសន្និដ្ឋានចូលចិត្តចុះ ៗ កឋិនទាននេះមានផលវិសេសជាងកាមិស-ទានទាំងអស់ បើលោកអ្នកទាំងឡាយមានសេចក្តីខ្វល់ខ្វាយចំណាយទ្រព្យធ្វើចីវរទាន ឬកឋិនទាននេះ ទោះបីប្រាថ្នាចង់បានសម្រេចឥដ្ឋផលយ៉ាងណា ៗ ក៏សឹងតែបានសម្រេចដូចសេចក្តីប្រាថ្នាយ៉ាងនោះៗ មិនខានឡើយ ។ តអំពីនេះទៅទៀត ខ្ញុំសូមសួរលោក តែមួយប្រស្នាទៀត

ទេ ៗ អើអនុត្តរ! អានិសង្សនៃកឋិនទាន ខាងទាយកអ្នកធ្វើដូច លោកបានសំដែងតែប៉ុណ្ណោះ ឬនៅមានដូចម្ដេចទៅទៀតដែរឬទេ? បើនៅមាន សូមខំមន្ដសំដែងឲ្យបានទូលំទូលាយ ដើម្បីពុទ្ធបរិស័ទទាំងឡាយស្ដាប់តទៅទៀតមើល ៗ

— ភន្ដេ មហាថេរៈ បពិត្រព្រះមហាថេដ៏ចំរើន! ឯអានិសង្សនៃកឋិនទានរបស់ទាយកអ្នកធ្វើនោះ នៅមានតទៅទៀត, វេលានេះខ្ញុំព្រះករុណានឹងចែកអានិសង្សនៃទាយកអ្នកបរិចាគកឋិនទាន ទុកក្នុងព្រះពុទ្ធសាសនាតាមបទព្រះគាថា ដែលព្រះបរមសាស្ដា ទ្រង់ទេសនាជាបទបាលីមានដើមថា. “យោ សោ វិនេយ្យ មច្ឆេរមលំ វិប្បសន្នេន ចេតសា ទជ្ជា កាលេន អរិយេសុ យត្ថ ទិន្នំ មហប្ផលំ កឋិនញ្ច ដូច្នេះជាដើម អធិប្បាយថា បុគ្គលណា មានចិត្តជ្រះថ្លា អាចកំចាត់បង់នូវមច្ឆរិយៈគឺសេចក្ដីកំណាញ់ ហើយស្រឡាញ់ក្នុងការកុសលផលបុណ្យបានលះនូវធនធាន ធ្វើកឋិនទានថ្វាយចំពោះព្រះអរិយសង្ឃ ឬសម្មតិសង្ឃក្នុងព្រះពុទ្ធសាសនា គួរជាទក្ខិណាចំរើនផលបាន, លុះអ្នកនោះទំលាយខន្ធចាកអត្តភាពជាមនុស្សនោះហើយ ក៏មានមុខទៅកាន់ស្ថានសួគ៌ទេវលោក សោយទិព្វសម្បត្តិជាឧឡារិកអធិកមហិមានៅក្នុងសួគ៌អស់កាលជាយូរអង្វែងវែងឆ្ងាយ សប្បាយក្សេមក្សាន្តសំកន្ត ដោយនាងទេពកញ្ញា ព្រៀងក៏ប្រគំគាល់បំរើស្នំទាំងយប់ថ្ងៃ

លុះដល់អស់កាលអាយុខ័យក៏ក្ស័យច្យុតស្រុតចុះមកកើត ក្នុងត្រកូលទាំងពីរគឺត្រកូលព្រាហ្មណ៍និងត្រកូលក្សត្រ ប្រកបដោយសម្បត្តិឥស្សរស័ក្តិយសខ្ពស់ក្រៃលែងជាងជននានា នៅនាលោកិយនេះ, ហើយអន្ទោលទៅអន្ទោលមកក្នុងសង្សារកើតតែក្នុងស្ថានទេវតានិងមនុស្សឧត្តម មិនប្រែទៅកើតក្នុងត្រកូលអ្នកហិនហោចឥតពង្ស ពុំដែលទៅកើតក្នុងទុគ្គតិភពចតុរាបាយទាំង ៤ អស់ ១ សែនកប្ប មិនដែលស្គាល់នូវសេចក្តីតោកយ៉ាកលំបាកក្រីក្រឡើយ បើបុគ្គលនោះចង់ប្រាថ្នាជាពុទ្ធភូមិក្តី ជាបច្ចេកភូមិក្តី ជាសាវកភូមិក្តី ក៏អាចសម្រេចដូចសេចក្តីប្រាថ្នា ឬចង់បានជាបកតិសាវកសាវិកា ក្នុងសំណាក់នៃព្រះអរិយមេត្រីដែលព្រះអង្គនឹងយាងមកត្រាស់ច្បាស់ក្នុងខាងមុខនោះ និមិត្តតែចូលទៅស្តាប់ស័ព្ទព្រះសទ្ធម្មវិសេសទេសនានៃព្រះអង្គ ក៏បានលុះដល់សម្បត្តិអរហត្តកាត់កិលេស, លុះដល់នូវធម៌ជាកំពូល គឺបាននូវបដិសម្ភិទា ៤ មានអត្ថប្បដិសម្ភិទាជាដើម បាននូវវិជ្ជានិងអភិញ្ញាទាំង ៦ ផង ហើយមានប្រាជ្ញាដ៏មុតថ្លាទាំងក្សៀវក្លាក្នុងឈានសមាបត្តិ ជាព្រះអរហត្តមានឥទ្ធិឫទ្ធិ មានតេជះឈ្នះនូវបញ្ចពិធមារទាំង ៥ ប្រការ ជាព្រះអរិយបុគ្គលដ៏ប្រសើរក្នុងព្រះពុទ្ធសាសនានៃព្រះអរិយមេត្រីសម្មាសម្ពុទ្ធ, នៅអស់កំណត់ក៏រលត់នូវខន្ធទៅកាន់នគរកែវ គឺអមតមហានិព្វាន ជាស្ថានក្សេមសុខប្រាសចាកចតុទុក្ខ គឺជាតិ ជរា ព្យាធិ មរណៈ ទៅតាមមិនដល់ ដោយ

អំណាចកុសលផលកឋិនទាននេះឯង ៗ សាធរ៉ បពិត្រសាធុសប្បុរសទាំងឡាយ ! ឯផលានិសង្សអង្គកឋិនទាននេះ ឃើញថាវិសេសប្លែកៗ ជាអនេកអនន្តពន់ប្រមាណ នៅមានពិស្តារក្នុងគម្ពីរបញ្ញាសជាតក ៗ អានុភាពនឹងផល់លោង យកមកទេសនាក្នុងវេលានេះ ក៏ជាការជ្រុលពេលា ហេតុនេះទើបប្រួបប្រួមពណ៌នាដោយសង្ខេប ទុកជាបែបនៃអ្នកមានសទ្ធា នឹងចង់ជ្រាបត្រួតត្រើតទៅ ៗ

ភន្តេ ថេរៈ បពិត្រព្រះមហាថេរដ៏ចំរើន ! ខ្ញុំព្រះករុណាបានសំដែងមកអំពីអានិសង្សកឋិនទាន មានន័យប្លែកផ្សេងៗ ក៏អស់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះ. សូមទានជ្រាប ៗ

២១ - សាធុ សាធុ កល្លោសិ អនុត្តរៈ ទីឃាយុកោ ហោតុ មាលអនុត្តរ ! លោកជាបុគ្គលខ្ទៀវក្លាសពន់ពេកណាស់ ចេះឆ្លើយប្រស្នាមកពីរោះក្បោះក្បាយ ល្មមលោកអ្នកសប្បុរសទាំងឡាយ មានចិត្តជ្រះថ្លាក្នុងការបំណាយទ្រព្យបរិច្ចាគធ្វើកឋិនទាន ដោយសេចក្តីត្រេកអរយ៉ាងក្រៃលែង ខ្ញុំសូមបួងសួងផល់គុណព្រះរតនត្រ័យ ឲ្យលោកមានជន្មាយុយឺនយូរអង្វែង ៗ សាធរ៉ បពិត្រសប្បុរសទាំងឡាយ ! លោកអ្នកគប្បីសន្និដ្ឋានចូលចិត្តចុះ ថាព្រះកឋិនទាននេះជាទានកម្រក្រៃក្រៃលែងជាងទាននានា ឯទានទាំងពួងក្រៅអំពីកឋិនទានសឹងពុំមានខែត្រហាម តាមតែចង់ធ្វើថ្ងៃណា វេលាណាក៏អាចធ្វើបានទាំងអស់ ឯកឋិនទាន

នេះពុំផុយបោះ ចំពោះមានខែត្រមានសម័យ ក្នុង ១ ឆ្នាំមានពុទ្ធានុញ្ញាតពិសេស បានតែ ២៩ ថ្ងៃទេ គឺពីខាងរនោចខែអស្សុជ ចាប់តាំងពីថ្ងៃ ១ រោចទៅដរាបដល់ថ្ងៃពេញបូណ៌មីខែកត្តិកជាទីបំផុត អស់រយៈកាលកឋិនហើយ, មួយទៀតកឋិនទាននេះ ចំពោះមានតែក្នុងពុទ្ធុប្បាទប៉ុណ្ណោះ ពុទ្ធុប្បាទោ សចេ នត្ថិ ជាបើកាលណាពុំមានព្រះពុទ្ធត្រាស់ហើយ កឋិនទាននេះសោតក៏ពុំមាន ពុទ្ធុប្បាទោ សចេ ហោតិ ជាបើកាលណាមានព្រះពុទ្ធមកត្រាស់ កឋិនំបិច វិជ្ជតិ ទើបកឋិនទានក៏មានក្នុងពុទ្ធុប្បាទនោះឯង ៗ ហេតុនោះកឋិនទាននេះជាទានកម្រក្រៃពេក ទាតុំ កឋិនំ បពិត្រសប្បុរសទាំងឡាយ ! កឋិនទានដែលយើងកល់គ្នាតប្បើឲ្យក្នុងវេលាកាលនៃកឋិន ពេញជាមានគតិគាប់ប្រសើរលើសលន់ បានកើតទាន់ព្រះពុទ្ធុប្បាទនៃព្រះគោតមបរមគ្រូជាហេតុ កឋិនវត្តក៏ដល់ព្រមល្អមបពិត្រកុំប្រមាទ ខំសង្វាត ៗ ស្វាហាប់សាង ៗ ស្វាហាប់សន្សំធ្វើទុកជាបច្ច័យទៅមុខឲ្យព្រះពុទ្ធ ១០ ព្រះអង្គទ្រង់បំបួសជាឯហិភិក្ខុ ភិក្ខុនី មិនចាំបាច់ស្វែងរកចីវរស្បង់សង្ឃាដី ព្រះជិនស្រីត្រាស់ថាតែ “ឯហិ” ប៉ុណ្ណោះ ក៏កើតត្រៃចីវរទិព្វបរិក្ខារមួយរំពេច បានសម្រេចមគ្គផលដល់ព្រះនិព្វានហោង ៗ

អាយស្មា អនុត្តរៈ ម្នាលអនុត្តរដ៏មានអាយុ ! យើងបានសំដែងព្រះសទ្ធម្មវិសេសទេសនា បុព្វ-វិសជ្ជនា មកអំពីរឿងកឋិនទានព្រម

ទាំងអាមិសនិស្សរបស់កប៉ិនទានជាច្រើនណាស់មកហើយ ក៏ល្មមសមគួរនឹងបញ្ចប់តែប៉ុណ្ណេះ, បព្វារិសជ្ជនាវិសាខេ កាលបើចប់ព្រះសទ្ធម្មវិសេសទេសនា បព្វារិសជ្ជនានេះហើយ សូមផ្សាយបុញ្ញកុសលគឺនូវបុណ្យដែលកើតអំពីអាមិសទាននិងធម្មទាន ជូនទៅដល់ដួងវិញ្ញាណនៃបុព្វការីបុគ្គលទាំងឡាយ មានមាតាបិតា ជីដូន ជីតា គ្រូឧបជ្ឈាយាចារ្យនូវញាតិកាទាំង៧សន្តាន សូមឲ្យលោកបានទទួលអនុមោទនាត្រេកអរចំពោះចំណែកបុណ្យនេះ មួយយ៉ាងទៀត សូមផ្សាយដល់ពពួកទេព្តាទាំងឡាយទាំង ១ សែនកោដិចក្រវាឡ សូមឲ្យលោកបានអញ្ជើញទទួលអនុមោទនា ចំពោះការកុសលផង កាលបើបានទទួលហើយ សូមឲ្យជួយបីបាច់រក្សាព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងដរាបទាល់តែ ៥ ពាន់ព្រះវស្សា ទាំងលោកអ្នកជាពុទ្ធបរិស័ទទាំងឡាយសោត ទោះបីបើលោកអ្នក មានប្រាថ្នានូវផលណាៗ គឺពុទ្ធភូមិ បច្ចេកភូមិ សាវកភូមិ ពុទ្ធមាតា ពុទ្ធបិតា ពុទ្ធបុត្ត កន្សែងសារពេជ្ញ ឬផលណាមួយក៏សូមឲ្យបានសម្រេចដូចសេចក្តីប្រាថ្នា នឹងសេចក្តីសុខគ្រប់ប្រការតាំងអំពីបច្ចុប្បន្នជាតិនេះ ដរាបដល់ព្រះនិព្វានជាអវសានជាតិ កុំបីឃ្លៀងឃ្លាតឡើយ ៗ អយំ ធម្មទេសនា រីព្រះធម៌ទេសនានេះសម្មត្តា សូមសន្មតថាចប់ ឯវំ ក៏សមគួរដោយវេលានេះឯងហោង ៗ

## ពិធីក្រាលគ្រងកឋិន

### ព្រះមហាឧត្តមវិជ្ជា កែ-អឿន (វីរិយប្បញ្ញោ)

*វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប រៀបរៀង*

### ព្រះទេពសត្ថា ស្បូរ-ហាយ ពិនិត្យកែសម្រួល

---

*កណ្ឌទីនេះ ខ្ញុំរៀបរៀងបាលីសម្រាប់វេរកឋិន តាមទំនងកិច្ចផ្សេងៗ មានពិធីក្រាលគ្រងកឋិនជាដើម ទុកជាបែបកណ្ឌបុណ្យកឋិនទាន ។*

## បាលីវេរកឋិនទានដល់ព្រះសង្ឃ

(១) ឥមំ ទុស្សំ កឋិនចីវរំ សង្ឃស្ស ទេម ។ ទុតិយម្បិ, តតិយម្បិ ។

*ប្រែថា "(បពិត្រព្រះតៃម្ដងសង្ឃដ៏ចំរើនអើយ) យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះ ជាសំពត់កឋិនចីវរ ប្រគេនចំពោះព្រះសង្ឃ ។ អស់វារៈពីរដងផង, អស់វារៈបីដងផង" ។*

*ឬនឹងវេរដោយបាលីផ្សេងទៀតក៏បាន ដូចមានខាងក្រោមនេះ*

(២) មយំ ភន្តេ ឥមំ វត្ថំ កឋិនចីវរំ សង្ឃស្ស និយ្យាទេម សាធុ ភន្តេ សង្ឃោ ឥមំ វត្ថំ កឋិនចីវរំ បដិគ្គណ្ហាតុ បដិគ្គ-

---

១ បាលីនេះបានដកស្រង់ពីសៀវភៅគិហិប្បដិបត្តិ ដែលធ្លាប់វេររៀងមក ។ ២ បាលីនេះរៀបរៀងថ្មី លោកអ្នកប្រើតាមចិត្តបែបណា តាមស្មគ្រចិត្ត ។

ហេត្វាន ឥមិនា អត្ករតុ ឥមា កឋិនទានបត្តិយោ សមិជ្ឈន្តុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ, តតិយម្បិ ។

*ប្រែថា “បពិត្រព្រះសង្ឃដ៏ចំរើន ! យើងខ្ញុំទាំងឡាយសូមវេរថ្វាយនូវសំពត់នេះ ជាកឋិនចីវរ ចំពោះព្រះសង្ឃ, បពិត្រព្រះសង្ឃដ៏ចំរើន ! សូមព្រះសង្ឃទទួលយកនូវសំពត់ជាកឋិនចីវរនេះ; លុះទទួលរួចហើយ សូមនិមន្តក្រាលគ្រងដោយសំពត់កឋិនចីវរនេះ; សូមចំណែកបុណ្យនៃកឋិនទានទាំងអម្បាលនេះសម្រេច ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង, អស់វារៈបីដងផង’ ។*

## បាលីវេរគ្រឿងបរិក្ខារជាបរិវារកឋិន

យេសម្ហាកំ(១) កឋិនំ គហិតំ កឋិនានិសង្សានិ តស្សេវ ទេម ។ ទុតិយម្បិ, តតិយម្បិ ។

*ប្រែថា “បពិត្រព្រះតៃម្ដងសង្ឃដ៏ចំរើនអើយ ! កឋិនរបស់យើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណា បានទទួលកាន់យកហើយ យើងខ្ញុំ*

១ បាលីនេះដកស្រង់ពីសៀវភៅគិហិប្បដិបត្តិ ដែលធ្លាប់វេររៀងមក ។

ទាំងឡាយ សូមវេរនូវគ្រឿងបរិក្ខារជាបរិវារនៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ ៗ អស់វារៈពីរដងផង, អស់វារៈបីដងផង" ។

ក្នុងអដ្ឋកថាពន្យល់ថា: បើទាយកវេរថា យេគម្ហាកំ ។ល។ តស្សេវ ទេម ដូច្នេះ, ព្រះសង្ឃមិនជាឥស្សរៈធំលើគ្រឿងបរិក្ខារជាបរិវារកឋិននោះទេ, បើទាយកចង់ឲ្យព្រះសង្ឃជាឥស្សរៈធំលើគ្រឿងបរិក្ខារទាំងនោះ ហើយទើបចង់បានផលានិសង្សច្រើន ត្រូវវេរដោយបាលីផ្សេងវិញ; ក្នុងទីនេះនឹងរៀបរៀងបាលីវេរគ្រឿងបរិក្ខារជាបរិវាររបស់កឋិនដល់ព្រះសង្ឃ ទុកជាបែបថា:

មយំ[១] ភន្តេ ឥមេ កឋិនបរិក្ខារេ សង្ឃស្ស និយ្យាទេម សាធុ ភន្តេ សង្ឃោ ឥមេ កឋិនបរិក្ខារេ បដិគ្គណ្ហាតុ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ, តតិយម្បិ ។

ប្រែថា: ‘ បពិត្រព្រះសង្ឃដ៏ចំរើន! យើងខ្ញុំទាំងឡាយសូមវេរថ្វាយនូវគ្រឿងបរិក្ខារជាបរិវារកឋិនទាំងឡាយនេះដល់ព្រះសង្ឃ, បពិត្រព្រះសង្ឃដ៏ចំរើន! សូមព្រះសង្ឃទទួលយកនូវគ្រឿងបរិក្ខារជាបរិវារកឋិនទាំងឡាយនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តី

---

១ បាលីនេះតែងថ្មីសម្រាប់វេរគ្រឿងបរិក្ខារជាបរិវារកឋិនដល់ព្រះសង្ឃ ។

សុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។ អស់ក:ព័រដងដង, អស់ការៈប័ដងដង” ។

## បាលីវេរផ្កាប្រាក់

មយំ ភន្តេ សទ្ធាបសន្នា ឥធ អារាមេ (សេនាសន-(១) ករណត្ថាយ) ឥមានិ ហិរញ្ញបុប្ផានិ សង្ឃស្ស ហរាម ។

សាធុ ភន្តេ សង្ឃោ វិនយានុរូបំ កប្បិយការកស្ស ហត្ថេ ឋបិតានិ ឥមានិ ហិរញ្ញបុប្ផានិ បដិជានាតុ មាតា-បិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ, តតិយម្បិ ។

ប្រែថា: “បពិត្រព្រះសង្ឃដ៏ចំរើន ! យើងខ្ញុំទាំងឡាយមានសទ្ធាជ្រះថ្លា បានលះបង់នូវផ្កាគឺហិរញ្ញវត្ថុទាំងឡាយនេះ សូមបរិណាដល់ព្រះសង្ឃ (ដើម្បីកសាងសេនាសនៈ) គង់វត្តនេះ ។ បពិត្រព្រះសង្ឃដ៏ចំរើន ! សូមព្រះសង្ឃទទួលដឹងនូវផ្កាគឺហិរញ្ញវត្ថុទាំងឡាយនេះ ដែលយើងខ្ញុំទាំងឡាយ បានដំកល់ទុកហើយក្នុងដៃនៃកប្បិយការកៈដ៏

---

១ បើកសាងវត្ថុអ្វី ត្រូវបញ្ចូលបាលីក្នុងវង់ក្រចកនេះ ។

សមគួរដល់វិន័យ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ គ្រប់ប្រការ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង, ដល់ញាតិទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។ អស់វារៈពីរដងផង, អស់វារៈបីដងផង” ។

កាលបើទាយកវេរអង្គកឋិន និងគ្រឿងបរិក្ខារជាបរិវារកឋិនរួចហើយ ត្រូវជំនុំសង្ឃចាត់ភិក្ខុពីររូប (គឺភិក្ខុដែលត្រូវសូត្រកឋិន) ឲ្យប្រកាសសេចក្ដីដល់ជំនុំសង្ឃ ដែលធ្លាប់ហៅថា ក្រើនកឋិន ។

ក្នុងទីនេះ និងរៀបរៀងជាបែបទុកតាមទម្លាប់ដែលធ្លាប់ធ្វើមក ។

## ភិក្ខុចាស់ក្រើនថាៈ

ភន្តេ បពិត្រជំនុំសង្ឃដ៏ចំរើន! អង្គកឋិនទាននេះ ជាកឋិនទានរបស់ (...[១]) មានបសាទសទ្ធាជ្រះថ្លាជឿជាក់ក្នុងបវរពុទ្ធសាសនា បានបរិច្ចាគធនធានចាត់ចែងធ្វើជាអង្គកឋិនទាននេះ ដង្ហែចូលមកវេរប្រគេនចំពោះព្រះសង្ឃ ដែលគង់ចាំព្រះវស្សាគ្រប់កំណត់ត្រៃមាសក្នុងអារាមវត្ត (...[២]) នេះ ជាសំពត់ដ៏ស្អាតបរិសុទ្ធផុតចាកមន្ទិល ហាក់ដូចជាសំពត់ទិព្វគោសេយ្យពស្ត្រ អណ្ដែតត្រសែតធ្លាក់ចុះអំពីអាកាស មកប្រតិស្ឋានក្នុងកណ្ដាលជំនុំសង្ឃនេះ និងបានស្មោះចំពោះភិក្ខុអង្គណាមួយ

---

១ ត្រូវបញ្ចូលនាមលោកអ្នកដែលមានសទ្ធាធ្វើកឋិនទាន ។ ២ ត្រូវបញ្ចូលឈ្មោះវត្តដែលហែចូលទៅ ។

នោះក៏ទេ ។ ហេតុនេះ បើភិក្ខុអង្គណាមានត្រៃចីវរទុព្វលភាព ដាច់ដាច ហើយធ្វៀវត្តាសក់ទីវិគ្គន៍កឋិនត្ថារកិច្ចគឺបេះបុព្វករណៈ ៧ មាតិកា ៨ បលិពោធ ២ ទីឯអានិសង្ស ៥ ប្រការជាដើម ដោយសព្វគ្រប់ ក៏សូមធ្វើយមក កុំបីអំមអៀមឡើយ ដំខុំសង្ឃទីឯបរិវត្តប្រគេនឲ្យភិក្ខុអង្គនោះក្រាលគ្រង់កឋិនកាលឥឡូវនេះហោង ។

## ភិក្ខុទី៤ ក្រើនតបទៅវិញថាៈ

### ឥទានិ ខោ ភន្តេ អតិសុន្ទរំ បកាសិតំ

បពិត្រព្រះករុណាដ៏ចំរើន! ពាក្យដែលព្រះករុណាម្ចាស់បានប្រកាសមកអម្បាញ់មិញនេះ ពិរោះណាស់ហើយ; ភិក្ខុសង្ឃ ដែលគង់ចាំវស្សាក្នុងអារាមនេះ សឹងមានត្រៃចីវរល្មមប្រើប្រាស់គ្រប់គ្រាន់ហើយ មិនទាន់ទុព្វលភាពទេ. តែបើតាមយោបល់របស់ខ្ញុំព្រះករុណា យល់ឃើញថា: គួរព្រះសង្ឃបរិវត្តប្រគេនដល់ព្រះតេជព្រះគុណ ( ..[១] ) ព្រោះលោកប្រកបដោយអង្គសម្បត្តិច្រើនប្រការ គឺ:

១ លោកជាព្រះថេរៈដ៏ឆ្លាតក្រៃច្រើន, បួសហើយអស់កាលយូរជាអធិការនៃសង្ឃ, ជាវិចារកៈរបស់សង្ឃ ។

---

១ ត្រូវបញ្ចូលនាមភិក្ខុ ដែលក្រាលកឋិន, ពាក្យនេះសម្រាប់ភិក្ខុដែលមានសមត្ថភាព ។

២ លោកជាអ្នកទ្រទ្រង់នូវធម្មវិន័យ ។

៣ លោកជាអ្នកឆ្លៀវឆ្លាតស្គាល់កឋិនត្ថារកិច្ចជាដើម ហើយមានសមត្ថភាពគួរនឹងក្រាលកឋិនបាន, បពិត្រព្រះសង្ឃគ្រប់ព្រះអង្គ ! បើព្រះសង្ឃយល់ព្រមតាមយោបល់របស់ខ្ញុំព្រះករុណា ដែលបានប្រកាសមកហើយនេះ សូមមេត្តាបន្លឺនូវសទ្ទសញ្ញាថា "សាធុ" គ្រប់ៗអង្គទៅហោង ។

កាលបើព្រមរួចហើយ ជំនុំសង្ឃត្រូវប្រគល់សំពត់កឋិនឲ្យទៅភិក្ខុអ្នកក្រាល ដោយញត្តិទុតិយកម្មវាចា តាមពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គថា:

សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ, សោ តុណ្ហាស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន

១ បាលីថា "ឥត្ថន្នាមស្ស" នេះត្រូវផ្លាស់ដាក់តាមនាមរបស់ភិក្ខុអ្នកក្រាលឲ្យរាល់បទ ។

កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

“បពិត្រព្រះតៃម្ដងសង្ឃដ៏ចំរើន! សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ, សំពត់កឋិននេះ កើតឡើងដល់សង្ឃហើយ ។ បើ (ការនេះ) មានកាលគួរដល់សង្ឃហើយ, សង្ឃគួរឲ្យសំពត់កឋិននេះ ទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន ។ នេះជាពាក្យផ្ដៀង ។ បពិត្រព្រះតៃម្ដងសង្ឃដ៏ចំរើន! សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ, សំពត់កឋិននេះ កើតឡើងដល់សង្ឃហើយ ។ (ឥឡូវ) សង្ឃឲ្យសំពត់កឋិននេះ ទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន ។ ការដែលឲ្យសំពត់កឋិននេះទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សំពត់កឋិននេះ សង្ឃឲ្យទៅភិក្ខុ (ឈ្មោះនេះ) ហើយ ដើម្បីក្រាលកឋិន ។ (ការនេះ) គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវការនេះ ដោយភាពដែលសង្ឃស្ងៀមយ៉ាងនេះ” ។

កាលបើសង្ឃសូត្រប្រគល់សំពត់កឋិន ដោយញត្តិទុតិយកម្មវាចា ដូច្នេះហើយ, បើសំពត់កឋិននោះបានយកធ្វើបរិកម្មសម្រេចមកជាស្បង់ចីពរសង្ឃាដីរួចហើយ ភិក្ខុត្រូវការក្រាលដោយស្បង់ឬចីពរឬសង្ឃាដី

គប្បីបច្ចុទ្ធរដកស្បង់ចីពរសង្ឃាដីចាស់ចេញ ហើយធ្វើកប្បពិន្ទុ-អធិដ្ឋានស្បង់ចីពរសង្ឃាដីថ្មីឡើង ។

## ឯពិធីដកដូច្នេះ

ដកសង្ឃាដីថា: ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ "អាត្មាអញដកនូវសង្ឃាដីនេះ" ។

ដកឧត្តរាសង្គ (ចីពរ) ថា: ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ "អាត្មាអញដកនូវឧត្តរាសង្គៈ (ចីពរ) នេះ" ។

ដកអន្តរវាសក: (ស្បង់) ថា: ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ "អាត្មាអញដកនូវស្បង់នេះ" ។

ដកចីពរ-ស្បង់-សង្ឃាដីរួចហើយ ត្រូវធ្វើកប្បពិន្ទុចីវរថ្មីដែលបំរុងក្រាលកប៉ិននោះ ត្រង់ជ្រុងមុមចីវរដោយពណ៌ ៣ យ៉ាងពណ៌ណាមួយដែលមានសំដែងក្នុងសិក្ខាបទស្រាប់ ។

## ឯពិធីពិន្ទុកប្បដូច្នេះ

ឥមំ ពិន្ទុកប្បំ ករោមិ "អាត្មាអញធ្វើនូវពិន្ទុកប្បនេះ" ។

តពីនេះត្រូវអធិដ្ឋានចីវរថ្មីឡើង, ពិធីអធិដ្ឋាននោះដូច្នេះ

អធិដ្ឋានសង្ឃាដីថា: ឥមំ សង្ឃាដឹ អធិដ្ឋាមិ ។ ទុតិយម្បិ,

តតិយម្បិ “អាត្មាអញអធិដ្ឋានខ្លួនសង្ឃាដីនេះ ។ អស់វារៈពីរដងផង, អស់វារៈបីដងផង” ។

អធិដ្ឋានឧត្តរាសង្គៈថា: ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។ ទុតិយម្បិ, តតិយម្បិ “អាត្មាអញអធិដ្ឋានខ្លួនឧត្តរាសង្គៈនេះ”... ។

អធិដ្ឋានអន្តរវាសកៈថា: ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។ ទុតិយម្បិ. តតិយម្បិ “អាត្មាអញអធិដ្ឋានខ្លួនអន្តរវាសក នេះ”... ។

កាលបើផ្តើមអធិដ្ឋានរួចហើយ ត្រូវគ្រាលកឋិនដោយចីវរណាមួយ តាមត្រូវការ ហើយគប្បីបញ្ចេញវាចាឲ្យជំនុំសង្ឃបានឮច្បាស់ ។

បើចង់គ្រាលដោយសង្ឃាដីថា: ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ “ខ្ញុំគ្រាលកឋិនដោយសង្ឃាដីនេះ” ។

បើចង់គ្រាលដោយចីពរថា: ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ “ខ្ញុំគ្រាលកឋិនដោយឧត្តរាសង្គៈ (ចីពរ) នេះ” ។

បើចង់គ្រាលដោយអន្តរវាសកៈថា: ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ “ខ្ញុំគ្រាលកឋិនដោយអន្តរវាសកៈ (ស្បង់) នេះ” ។

កាលបើភិក្ខុបានគ្រាលកឋិនតាមបែបនេះរួចហើយ ត្រូវចូលទៅជិតសង្ឃឬគណៈបុគ្គល ត្រង់ចីពរស្អាតមានអត្ថិយប្រហោង ប្រណម្យអញ្ជលីឡើង ពោលប្រាប់ឲ្យលោកទាំងនោះ អនុមោទនាថា: អត្ថតំ

អាវុសោ[១] សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទថ "ម្នាលលោកដ៏មានអាយុ! កឋិនរបស់សង្ឃខ្ញុំក្រាលរួចហើយ, ការក្រាលកឋិន (នុះ) ប្រកបដោយធម៌, សូមលោកទាំងឡាយអនុមោទនាចុះ" ។

ចំណែកខាងភិក្ខុអ្នកអនុមោទនាវិញ ត្រូវគ្រងចីវរស្ពាយខាង អង្គុយច្រហោងប្រណម្យអញ្ជលីឡើងពោលអនុមោទនាថា: អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទាម "បពិត្រលោកម្ចាស់ដ៏ចំរើន កឋិនរបស់សង្ឃ លោកក្រាលរួចហើយ, ការក្រាលកឋិន (នុះ) ប្រកបដោយធម៌ យើងសូមអនុមោទនា" ។

ឬនឹងអនុមោទនាមួយបែបទៀតក៏បាន: អត្ថតំ ភន្តេ[២] សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អនុមោទាម[៣] "បពិត្រ[៤] ព្រះករុណាដ៏ចំរើន! កឋិនរបស់សង្ឃ ដែលសង្ឃបានឲ្យហើយដល់លោកៗ បានក្រាលហើយ, កឋិនដែលលោកបានក្រាលហើយនេះ ជាធម៌សមគួរតាមពុទ្ធានុញ្ញាត, ខ្ញុំព្រះករុណាទាំងឡាយ សូមអនុមោទនា គឺថាត្រេកអរតាមនូវកឋិន" ។

ចប់វិធីក្រាលគ្រងកឋិន

---

១ បើភិក្ខុអ្នកក្រាលវ័ស្សាធំជាងត្រូវថា ភន្តេ ប្រែថា បពិត្រលោកទាំងឡាយដ៏ចំរើន ។
២ បើភិក្ខុអ្នកអនុមោទនាចាស់ជាង ត្រូវថា អាវុសោ ប្រែថា ម្នាលលោកដ៏មានអាយុ ។
៣ បើភិក្ខុតែ ១រូបអនុមោទនាថា អនុមោទាមិ ប្រែថា ខ្ញុំសូមអនុមោទនា ។ ៤ ប្រែថា នេះគឺប្រែសម្រួលសេចក្ដី បើភិក្ខុគាប់ចិត្តយកតាមបែបណាក៏គប្បីយកតាមបែបនោះចុះ ។